TRUTH CENTERED TRANSFORMATION

MODULE THREE



# ការស្វែងយល់ពីសេចក្ដីពិតរបស់ព្រះជាម្ចាស់ និង សេចក្ដីកុហករបស់មារសាតាំង

# មគ្គុទ្ទេសក៍សម្រាប់គ្រូបង្រៀន

reconciledworld

This is a training tool designed by Reconciled World. visit TCTprogram.org for more information

# មាតិកា


**មេរៀនទី១៖ តើយើងត្រូវបានផ្លាស់ប្រែឬ? ........ ៣**

សេចក្តីផ្តើម ........ ៣

ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ........ ៧

រំឭកពីជំពូកទី១ ........ ៨

ការផ្លាស់ប្រែនៅប្រទេសហ្វីជី ........ ៩

**កាតរូបភាពស្តីអំពីប្រទេសហ្វីជី ........ ១០**

ជំពូកទី១ និង ទី២ ........ ១៣

ការឆ្លុះបញ្ចាំង ........ ១៣

**មេរៀនទី២៖ យើងត្រូវធ្វើជាអ្នកចាត់ចែងស្នាព្រះហស្តទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ........ ១៤**

សេចក្តីផ្តើម ........ ១៤

ដំណើររឿង ........ ១៥

ការសិក្សាព្រះគម្ពីរ ........ ១៦

ទំនាក់ទំនងត្រឹមត្រូវជាមួយស្នាព្រះហស្តដែលព្រះជាម្ចាស់បានបង្កើតមក ........ ១៨

**កាតរូបភាពពីស្នាព្រះហស្តដែលព្រះជាម្ចាស់បានបង្កើត ........ ១៩**

**មេរៀនទី៣៖ យើងអាចផ្លាស់ប្រែអនាគតរបស់យើងបាន ........ ២២**

សេចក្តីផ្តើម ........ ២២

ការបង្កើតឲ្យមានការផ្លាស់ប្រែ ........ ២៣

ធ្វើជាមនុស្សដែលនាំមកនូវការផ្លាស់ប្រែ ........ ២៤

ការសន្និដ្ឋាន ........ ៣០

អនុវត្តន៍ ........ ៣០

**មេរៀនទី៤៖ ព្រះជាម្ចាស់បានប្រទានមកឲ្យយើងច្រើនណាស់ ........ ៣១**

សេចក្តីផ្តើម ........ ៣១

ការសិក្សាព្រះគម្ពីរ ........ ៣២

យកឈ្នះលើការដោះសាររបស់យើង ........ ៣២

យើងត្រូវតែចាប់ផ្តើមឃើញអ្វីៗទាំងអស់ថា ព្រះជាម្ចាស់បានប្រទានមកឲ្យយើង ........ ៣៣

កសិករ ........ ៣៤

**មេរៀនទី៥៖ សាតាំងគឺជាមេកុហក ....................................................................... ៣៦**
សេចក្តីផ្តើម ................................................................................................ ៣៦
តើសាតាំងប្រាប់ការកុហកបែបណាខ្លះ? ................................................................ ៣៧
តើការកុហកនេះមានផលប៉ះពាល់អ្វីខ្លះ? ................................................................ ៣៩
តើយើងអាចកម្ចាត់ពាក្យកុហកដោយរបៀបណា? ..................................................... ៤០
**មេរៀនទី៦៖ ការវាយតម្លៃពីតម្រូវការ ....................................................................... ៤២**
សេចក្តីផ្តើម ................................................................................................ ៤២
គ្រួសារ ...................................................................................................... ៤៣
សហគមន៍ .................................................................................................. ៤៤
ការដាក់អាទិភាពលើគម្រោងនីមួយៗ ..................................................................... ៤៥

## មេរៀនទី១

# តើយើងត្រូវបានផ្លាស់ប្រែឬ?

**គោលបំណង**

១. ស្វែងយល់ថា ក្នុងនាមជាគ្រិស្តបរិស័ទ ជីវិតរបស់យើងគួរត្រូវបានផ្លាស់ប្តូរនៅពេលដែលយើងរស់នៅដោយស្តាប់បង្គាប់ព្រះជាម្ចាស់

២. ចំណាយពេលវាយតម្លៃ ថាតើយើងកំពុងតែអនុវត្តអ្វីដែលយើងដឹងពីក្រិត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ហើយថាតើយើងពិតជាឃើញនូវការផ្លាស់ប្តូរមែន ឬយ៉ាងណា

**សម្ភារៈឧបទេសដែលត្រូវការ**

- កញ្ចប់រូបភាពជំនួយដល់ការសិក្សា – រូបភាពដែលផ្តិតយកចេញពីវីដេអូនៅប្រទេស ហ្វីជី (Fiji)
- សន្លឹកក្រដាសធំៗ និងខ្មៅដៃពណ៌

## សេចក្តីផ្តើម

សូមអានសាច់រឿងខាងក្រោម

**រឿងទី១ ៖ ប្រទេសរ៉្វាន់ដា** (Rwanda)




រ៉្វាន់ដា គឺជាប្រទេសតូចមួយដែលមានប្រជាជន ៨.២ លាននាក់។ ១០០ឆ្នាំមុន គ្មានគ្រិស្តបរិស័ទណាម្នាក់ទេ ប៉ុន្តែមកដល់ដើមឆ្នាំ១៩៩០ គឺមានក្រុមជំនុំគ្រប់ទីកន្លែង៖ ៨៥%នៃប្រជាជននៅក្នុងប្រទេស រ៉្វាន់ដា គឺជាគ្រិស្តបរិស័ទ។ វាបានចាប់ផ្តើមឡើងដោយមានការផុសផុល និងបានរីករាលដាលតាមប្រទេសអាហ្វ្រិកខាងកើតនៅក្នុងឆ្នាំ១៩៤០ ដែលមានមនុស្សរាប់លាននាក់ទទួលបានការសង្គ្រោះ។ នៅក្នុងឆ្នាំ១៩៩១ និង១៩៩៣ មានព្រឹត្តិការណ៍ផ្សាយដំណឹងល្អដ៏ធំមួយ ដែលបានប្រព្រឹត្តឡើងនៅទីនោះ ហើយមានមនុស្សរាប់ពាន់នាក់បានទទួលការសង្គ្រោះ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៩៤ មានការសម្លាប់រង្គាលយ៉ាងព្រៃផ្សៃបានកើតឡើង ដែលមានមនុស្ស១លាននាក់បានស្លាប់ និង២លាននាក់ត្រូវបានបង្ខំឲ្យចេញពី

ប្រទេសរ៉្វាន់ដា។ ការសម្លាប់នោះគឺបណ្តាលមកពីលទ្ធផលនៃការស្អប់ និងរើសអើងជាតិសាសន៍។ វាបានកើតឡើងដោយការប្រឈមមុខដាក់គ្នាដោយប្រើកាំបិត មិនមែនដោយគ្រាប់បែក ឬកាំភ្លើងនោះទេ។ នៅក្នុងប្រទេសដែលមានប្រជាជន ៨៥% ជាគ្រិស្តបរិស័ទ មានគ្រិស្តបរិស័ទ២នាក់បានឈរទល់មុខគ្នាហើយសម្លាប់គ្នាដោយកាំបិត។ មានរឿងរ៉ាវដ៏អាក្រក់ជាច្រើនបានកើតឡើង មិនគួរឲ្យនឹកស្មានដល់។ ដំណឹងដែលថាមានស្ត្រីៗត្រូវបានចាប់រំលោភ និងសម្លាប់នៅចំពោះមុខកូនៗរបស់ពួកគេ ឬម្តាយត្រូវបានបង្ខំឲ្យកប់កូនៗរបស់ខ្លួនទាំងរស់ បានក្លាយជារឿងធម្មតា។ គ្មាននរណាម្នាក់នៅក្នុងពិភពលោកជឿថា គ្រិស្តបរិស័ទ២ក្រុមអាចស្អប់គ្នាខ្លាំងយ៉ាងនោះទេ។

**រឿងទី២៖ សហរដ្ឋអាមេរិក**

នៅទូទាំងសហរដ្ឋអាមេរិក អ្នកអាចឃើញមានក្រុមជំនុំនៅគ្រប់ទីកន្លែង។ អ្នកអាចស្តាប់វិទ្យុគ្រិស្តបរិស័ទ និងមើលកម្មវិធីទូរទស្សន៍គ្រិស្តបរិស័ទស្ទើរតែគ្រប់ទីកន្លែងដែលអ្នកទៅ។ នៅក្នុងសហគមន៍ភាគច្រើនមានសាលា មហាវិទ្យាល័យ និងសាកលវិទ្យាល័យគ្រិស្តបរិស័ទជាច្រើន។ មានសៀវភៅ គេហទំព័រ ទស្សនាវដ្តី និងការសែតគ្រិស្តបរិស័ទជាច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសហរដ្ឋអាមេរិកមានទារក ១,៥ លាននាក់ ត្រូវបានសម្លាប់ជារៀងរាល់ឆ្នាំដោយការរំលូតកូន។ ពាក់កណ្តាលនៃជីវិតអាពាហ៍ពិពាហ៍ទាំងអស់បានបញ្ចប់ដោយការលែងលះគ្នា។ តួលេខទាំងអស់នេះ មិនមែនកើតឡើងលើអ្នកមិនជឿតែប៉ុណ្ណោះទេ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលជាងនេះទៅទៀតគឺ អត្រានៃការលែងលះ និងការរំលូតកូនស្ទើរតែដូចគ្នាសម្រាប់គ្រិស្តបរិស័ទដែរ។

**រឿងទី៣៖ ប្រទេសប្រេស៊ីល**




នៅសហគមន៍តាមដងទន្លេអាម៉ាស្សូនគឺជាតំបន់ក្រីក្រ និងដាច់ស្រយាល។ មានវិធីតែមួយគត់ដែលអាចទៅទីនោះបានគឺតាមរយៈទូក។ កាលពី៣០ឆ្នាំមុន គ្មានគ្រិស្តបរិស័ទណាម្នាក់នៅក្នុងសហគមន៍នេះទេ។ ៣០ឆ្នាំមុន មានបេសកជនបានមកតំបន់ទាំងនេះដោយទូក និងបានប្រកាសព្រះបន្ទូល ហើយប្រជាជនបានទទួលការសង្គ្រោះ។ មានបេសកជនបានមករស់នៅទីនោះមួយរយៈពេលដោយដាំក្រុមជំនុំ ហើយក៏បានទៅសហគមន៍បន្ទាប់។ បច្ចុប្បន្ននេះ នៅពេលដែលអ្នកទៅទីនោះ អ្នកនឹងស្រក់ទឹកភ្នែកដោយសារតែអ្នកភូមិនៅទីនោះមានជីវភាពក្រីក្រជាខ្លាំង។ ក្រុមគ្រួសារនៅភូមិនោះ ស្ទើរតែមិនមានអាហារបរិភោគគ្រប់គ្រាន់។ មានវិធីសាស្ត្រមួយដែលក្រុមគ្រួសារទាំងនោះទទួលបានប្រាក់គឺ លក់កូនស្រីរបស់ខ្លួនឲ្យទៅធ្វើជាស្រីពេស្យា នៅពេលដែលពួកគេមានអាយុទើប



តែ១២ ឬ១៣ឆ្នាំ។ ឪពុករបស់ពួកគេ បានថែរក្សាកូនស្រីរបស់ខ្លួនសម្រាប់អ្នកមាននៅក្នុងសហគមន៍នោះ។ ទោះបីឪពុកជាគ្រិស្តបរិស័ទក៏ដោយ ក៏ពួកគេធ្វើដូចគ្នាដែរ គឺលក់កូនស្រីរបស់ពួកគេដើម្បីប្រាក់។

- តើមានអ្វីបានកើតឡើង ចំពោះសាច់រឿងនីមួយខាងលើនេះ?
- តើរឿងទាំងអស់នេះគួរឲ្យភ្ញាក់ផ្អើលដែរឬទេ? ហេតុអ្វី បានជាគួរឲ្យផ្ញាក់ផ្អើល?
- តើអ្នកគិតថាព្រះជាម្ចាស់មានអារម្មណ៍យ៉ាងណាចំពោះស្ថានភាពទាំងអស់នេះ? ហេតុអ្វី?

**រឿងទី៤៖ ភូមិនៅតំបន់ភ្នំ**

មានភូមិតូចមួយនៅលើភ្នំ។ ភូមិនោះស្ថិតនៅក្នុងតំបន់ក្រីក្រមួយនៃប្រទេស ហើយមនុស្សរស់នៅមានលក្ខណៈសាមញ្ញណាស់។ ពួកគេមិនមានអាហារបរិភោគគ្រប់គ្រាន់នោះទេ។ ពួកគេរស់នៅដោយពឹងផ្អែកលើអាកាសធាតុ ដែលអាកាសធាតុជាអ្នកកំណត់ថា តើពួកគេនឹងមានគ្រប់គ្រាន់ ឬពួកគេនឹងប្រឈមមុខនឹងកង្វះខាតជារៀងរាល់ឆ្នាំ? ពួកគេគ្មានបង្គន់ដើម្បីប្រើប្រាស់ ហើយរស់នៅក្នុងផ្ទះសាមញ្ញធម្មតា។ ពួកគេមិនមែនជាមនុស្សដែលមិនរីករាយនឹងជីវិតនោះទេ ប៉ុន្តែខិតខំប្រឹងប្រែងធ្វើការជាខ្លាំងនៅលើដីស្រែរបស់ពួកគេ នឹងខិតខំតស៊ូពីមួយឆ្នាំទៅមួយឆ្នាំ។

កាលពី៣០ឆ្នាំមុន មានបេសកជនបានមកដល់ទីនេះជាលើកដំបូង និងបានប្រាប់ពួកគេពីព្រះគ្រិស្ត។ នៅពេលដែលពួកគេស្តាប់ និងបានស្វែងយល់ពីព្រះគ្រិស្តហើយ ពួកគេក៏បានចាប់ផ្តើមទទួលជឿ និងមនុស្សជាច្រើនបានក្លាយជាគ្រិស្តបរិស័ទ។ បេសកជនបានជួយប្រជាជននៅទីនោះដាំក្រុមជំនុំ។ ប្រជាជននៅទីនោះបានមកចូលរួមក្នុងក្រុមជំនុំយ៉ាងទៀតទាត់។ ពួកគេរីករាយដោយសារតែពួកគេបានដឹងថា នៅពេលដែលពួកគេស្លាប់ទៅ ពួកគេនឹងទៅស្ថានសួគ៌ ហើយពួកគេទន្ទឹងរង់ចាំថ្ងៃដ៏ពិសេស នៅពេលដែលពួកគេបានជួបជាមួយនឹងព្រះសង្គ្រោះរបស់ពួកគេ។

បេសកជនក៏បានចាកចេញពីតំបន់នោះ ហើយក្រុមជំនុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកដឹកនាំក្នុងតំបន់។ ៣០ឆ្នាំបន្ទាប់ បេសកជនក៏បានត្រឡប់មកវិញ។ ក្រុមជំនុំបានរីកចម្រើន ហើយប្រជាជនបានប្ដេជ្ញាថានឹងបន្តជួបជុំគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ភូមិនៅទីនោះនៅតែដដែល។ ពួកគេនៅតែក្រីក្រ ហើយនៅតែពឹងផ្អែកលើអាកាសធាតុដែលជាអ្នកសម្រេចពីជីវិតរបស់ពួកគេ ថាតើពួកគេនឹងអត់ឃ្លាន ឬមានអ្វីគ្រប់គ្រាន់សម្រាប់បរិភោគជារៀងរាល់ឆ្នាំ។ ពួកគេនៅតែគ្មានបង្គន់សម្រាប់ប្រើនៅក្នុងសហគមន៍។ ពួកគេមានតែការផ្លាស់ប្តូរបន្តិចប៉ុណ្ណោះ។

- តើមានអ្វីបានកើតឡើងនៅក្នុងសាច់រឿងនេះ?
- តើរឿងនេះគួរឲ្យភ្ញាក់ផ្អើលដែរឬទេ? ហេតុអ្វី?
- តើមានអ្វីដែលដូចគ្នារវាងរឿងនេះ និងសាច់រឿងផ្សេងទៀត?

ជាមួយគ្នានេះដែរ សាច់រឿងចុងក្រោយគេគឺហាក់ដូចជាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលសម្រាប់យើង ក៏ដូចជាសាច់រឿងទាំងបីខាងលើ ដោយសារតែវាជារឿងរ៉ាវទូទៅ។ ប៉ុន្តែវាក៏ដូចជាសាច់រឿងផ្សេងទៀតដែរ នៅពេលដែលគ្រិស្តសាសនាបានជួយសង្គ្រោះមនុស្ស វាមិនបានផ្លាស់ប្តូរជីវិតរបស់ពួកគេនៅឡើយទេ។ ព្រះជាម្ចាស់ចង់ឲ្យជីវិតរបស់យើងខុសប្លែកពីមុន នៅលើផែនដីនេះ គឺមិនគ្រាន់តែនៅពេលដែលយើងទៅស្ថានសួគ៌ប៉ុណ្ណោះទេ។

## ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់

សូមអាន ទុតិយកថា ៣០៖១១-២០

- តើព្រះជាម្ចាស់ពណ៌នាពីក្រឹត្យវិន័យរបស់ទ្រង់ដោយរបៀបណា? តើក្រឹត្យវិន័យទាំងនោះពិបាក ឬក៏ងាយស្រួល?
- នៅក្នុងខ១៥ តើមានជម្រើសអ្វីខ្លះនៅចំពោះមុខយើង? តើអ្នកចូលចិត្តមួយណាជាង?
- តើអ្វីដែលនាំមកនូវជីវិត និងព្រះពរ? (ខ១៥-១៦)
- តើអ្វីដែលនាំមកសេចក្តីស្លាប់ និងបណ្តាសា? (ខ១៧-១៨)
- តើព្រះជាម្ចាស់ចង់ឲ្យយើងរើសយកអ្វី? (ខ១៩)

សូមអាន ទុតិយកថា ២៨៖១-១៤

- តើមានអ្វីកើតឡើង ប្រសិនបើយើងគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់?
- តើព្រះបន្ទូលសន្យាទាំងនេះ គឺសម្រាប់ជីវិតបន្ទាប់ពីយើងស្លាប់ទៅ ឬក៏សម្រាប់ជីវិតនៅលើផែនដីនេះ?

សូមអាន ទុតិយកថា ២៨៖១៥-១៩

- តើមានអ្វីកើតឡើង ប្រសិនបើយើងមិនគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់?

ព្រះជាម្ចាស់បានបង្កើតក្រឹត្យវិន័យជាច្រើនដែលប្រាប់យើងពីរបៀបដែលយើងគួររស់នៅ។ មានក្រឹត្យវិន័យសីលធម៌ដែលដឹកនាំឲ្យខ្លួនយើងល្អ។ ឧទាហរណ៍៖ «អ្នកមិនត្រូវប្រព្រឹត្តអំពើផិតក្បត់ឡើយ»។ មានក្រឹត្យវិន័យដែលចែងពីការបង្កើត និងធម្មជាតិ ដើម្បីរក្សាអ្វីដែលយើងអាចមើលឃើញ។ ឧទាហរណ៍ នៅក្នុងមួយថ្ងៃមាន២៤ម៉ោង ឬ រុក្ខជាតិត្រូវការទឹកដើម្បីលូតលាស់។

នៅពេលដែលយើងគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ យើងនឹងឃើញជីវិតរបស់យើងកាន់តែប្រសើរឡើង។ យើងត្រូវតែយល់ពីក្រឹត្យវិន័យ ឬច្បាប់ទាំងនេះ ដើម្បីចាប់ផ្តើមអនុវត្តវានៅក្នុងជីវិតរបស់យើង។ នៅពេលដែលយើងធ្វើដូច្នោះ យើងនឹងឃើញព្រះជាម្ចាស់ប្រទានពរដល់ជីវិតរបស់យើងជាមិនខាន។

## រំឭកជំពូកទី១

សូមមើលទៅកាន់រូបទី ៣ នៅក្នុងជំពូកទី១ មេរៀនទី១៖



- តើរូបភាពទាំងនេះ តំណាងឲ្យទំនាក់ទំនងអ្វីខ្លះ?
- តើព្រះជាម្ចាស់មានក្រឹត្យវិន័យ ឬគោលការណ៍លើផ្នែកទាំងនេះដែរឬទេ? តើអ្នកអាចនឹកឃើញពីចំណុចអ្វីខ្លះ?

ព្រះជាម្ចាស់មានក្រឹត្យវិន័យស្ដីពីរបៀបដែលយើងប្រព្រឹត្តនៅក្នុងទំនាក់ទំនងទាំងនេះ។ ទ្រង់បានប្រទានឲ្យយើងនូវគោលការណ៍ដើម្បីជួយយើងឲ្យទទួលបានជោគជ័យនៅក្នុងផ្នែកទាំងនេះ និងជួយស្ដារឡើងវិញនូវទំនាក់ទំនងដែលបាក់បែក។ ពិតណាស់ វាមិនល្អឥតខ្ចោះនោះទេ ទាល់តែព្រះយេស៊ូត្រឡប់មកសាជាថ្មីម្ដងទៀត ប៉ុន្តែពួកគេត្រូវតែកែតម្រូវឲ្យល្អប្រសើរឡើង។

នៅក្នុងវគ្គបណ្ដុះបណ្ដាលមុននេះ យើងបានបង្រៀនពីសម័យកំណែទម្រង់គ្រិស្តសាសនា។ នៅពេលនោះ ប្រជាជនក្រីក្រជាខ្លាំង។ លើកលែងតែម្ចាស់ដីជាអ្នកមាន ឬគ្រួសាររាជវង្សប៉ុណ្ណោះ មនុស្សភាគច្រើនគឺក្រីក្រ និងអត់ឃ្លាន។

ជាង៤០០ឆ្នាំមុន សម័យកំណែទម្រង់គ្រិស្តសាសនាបានមកដល់អឺរ៉ុបខាងជើង។ នេះជាលើកដំបូង ដែលមនុស្សអានព្រះគម្ពីរដោយខ្លួនឯង។ ពួកគេមិនចាំបាច់ឲ្យបូជាចារ្យប្រាប់ពួកគេថាព្រះគម្ពីរចែងពីអ្វីនោះឡើយ។ ពួកគេចាប់រៀនពីក្រឹត្យវិន័យស្ដីពីសីលធម៌ និងធម្មជាតិ ដែលព្រះជាម្ចាស់បានបង្កើតសម្រាប់សកលលោករបស់ទ្រង់។ ពេលវេលាកាន់តែកន្លងផុតទៅ ក្រឹត្យវិន័យទាំងនេះត្រូវបានបង្រៀនកាន់តែច្រើនឡើងៗនៅក្នុងក្រុមជំនុំ និងសាលារៀន។ ជាមួយនឹងការបង្រៀននេះ មនុស្សចាប់ផ្ដើមផ្លាស់ប្រែ ហើយពួកគេចាប់ផ្ដើមរស់នៅក្នុងជីវិតដែលពឹងផ្អែកទៅលើគំនិតថ្មីៗដែលទើបនឹងបានរៀននេះ។ ឧទាហរណ៍៖ ពួកគេយល់ច្បាស់ថា ព្រះជាម្ចាស់បានប្រាប់ពួកគេឲ្យខិតខំប្រឹងប្រែងធ្វើការសម្រាប់ទ្រង់ មិនមែនសម្រាប់មនុស្សទេ (អេភេសូ ៦៖៧)។ ហើយពួកគេក៏យល់ច្បាស់ថា យើងត្រូវចេះឲ្យ និងជួយទុក្ខធុរៈគ្នាទៅវិញទៅមក។

នៅពេលដែលពួកគេផ្លាស់ប្រែ សហគមន៍របស់ពួកគេក៏ផ្លាស់ប្រែដែរ។ ស្បៀងអាហារក៏កាន់តែបានផលច្រើន និងមានការចែករំលែកនូវធនធានដែលគេមានដល់គ្នាផងដែរ។ គ្រួសារ និងសហគមន៍ត្រូវបានពង្រឹង ហើយមានមនុស្សជាច្រើនបានទៅសាលារៀន នឹងទទួលបានចំណេះដឹង។ ពីប្រទេសជាតិមួយទៅប្រទេសជាតិមួយនៅក្នុងសហគមន៍អឺរ៉ុបភាគខាងជើង បានរួចផុតពីភាពក្រីក្រ។

ដោយគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ប្រជាជាតិនានានៅអឺរ៉ុបខាងជើងបានក្លាយជាអ្នកមាន។ ការបដិសេធក្រឹត្យវិន័យរបស់ព្រះជាម្ចាស់បង្កើតឲ្យមានភាពក្រីក្រ។ ប្រសិនបើយើងចង់គេចចេញពីភាពក្រីក្រ យើងត្រូវតែចាប់ផ្ដើមស្វែងយល់ឲ្យបានច្បាស់ និងអនុវត្តនូវគោលការណ៍ទាំងនេះ។

យើងត្រូវបានឲ្យនូវព្រះគម្ពីរដែលបានបង្ហាញពីក្រឹត្យវិន័យទាំងអស់នៃព្រះជាម្ចាស់។ យើងត្រូវតែអនុវត្តវានៅក្នុងផ្នែកនៃជីវិតរបស់យើង។ វាមិនគ្រប់គ្រាន់នោះទេ ដោយគ្រាន់តែមកក្រុមជំនុំនៅថ្ងៃអាទិត្យតែប៉ុណ្ណោះ។ ព្រះជាម្ចាស់ចង់ឲ្យយើងគោរពទ្រង់រៀងរាល់ពេលវេលា។ នៅពេលដែលយើងធ្វើដូច្នោះ នោះយើងនឹងឃើញជីវិតរបស់យើងកាន់តែរីកចម្រើនឡើង។ វាមិនមែនបានន័យថា ជីវិតរបស់យើងមិនតែងតែងាយស្រួលនោះទេ។ ប្រសិនបើយើងមើលទៅជីវិតរបស់លោកប៉ូល យើងឃើញថាគាត់តែងតែជួបប្រទះនូវទុក្ខលំបាកផ្សេងៗ។ ប៉ុន្តែព្រះជាម្ចាស់បានសន្យានឹងប្រទានពរដល់យើង នៅពេលដែលយើងដើរតាមទ្រង់។ សូម្បីតែលោកប៉ូលក៏ពេញចិត្ត និងបានរកឃើញនូវអំណរនៅក្នុងទុក្ខលំបាកដែលគាត់ជួបប្រទះដែរ។

## ការផ្លាស់ប្រែនៅប្រទេសហ្វីជី

ចូរប្រើកាតរូបភាពដែលផ្ដិតចេញពីវីដេអូ ដើម្បីប្រាប់សាច់រឿងដូចខាងក្រោមពីប្រទេសហ្វីជី។

នៅពេលដែលសិស្សស្ដាប់សាច់រឿង សុំឲ្យពួកគេត្រៀមខ្លួនដើម្បីឆ្លើយសំណួរដូចខាងក្រោម៖

១. តើមនុស្សចាប់ផ្ដើមគោរពព្រះជាម្ចាស់តាមរបៀបណាខ្លះ?
២. តើពួកគេឃើញថាព្រះជាម្ចាស់ប្រទានពរដល់ពួកគេតាមរបៀបណាខ្លះ?

# ភាគរូបភាពស្ដីអំពីប្រទេសហ្វីជី

| | |
|---|---|
| ១. សេចក្ដីផ្ដើម<br> | ប្រទេសហ្វីជី កើតឡើងដោយកោះ ៣២២។ វាជាតំបន់ទេសចរណ៍ ដែលមានមនុស្សល្បីៗជាច្រើនបានមកលេងនៅថ្ងៃឈប់សម្រាក។ ចំណូលភាគច្រើនគឺបានមកពីទេសចរ។ មានមនុស្ស ៨៥០០០០នាក់ ដែលរស់នៅប្រទេសហ្វីជី ដែលពាក់កណ្ដាលជាប្រជាជនហ្វីជី ហើយ ពាក់កណ្ដាលទៀតជាជនជាតិឥណ្ឌា។ |
| ២. បញ្ហាដែលពួកគេបានជួបប្រទះ<br> | នៅក្នុងខែឧសភា ឆ្នាំ២០០០ រដ្ឋាភិបាលត្រូវបានក្ដោបក្ដាប់ ហើយមន្ត្រីរបស់រដ្ឋាភិបាលត្រូវបានចាប់ឃុំខ្លួនដោយភ្ជង់នឹងកាំភ្លើងអស់រយៈពេល ៥៦ថ្ងៃ។ នៅតាមដងផ្លូវមានកុបកម្ម ហើយប្រជាជនសម្លាប់គ្នាទៅវិញទៅមក។  ពួកទាហានបានបានវាយប្រហារគ្នាទៅវិញទៅមក។ ទោះបីជាសមាជិករបស់រដ្ឋាភិបាលត្រូវបានដោះលែងក៏ដោយ ក៏ប្រទេសនោះនៅតែមានចលាចល។ ភ្ញៀវទេសចរឈប់មកលេង ដូច្នេះ ប្រជាជនមិនអាចលក់ដូរទៅឲ្យភ្ញៀវទេសចរបានទៀតនោះទេ។ |
| ៣. ក្រុមជំនុំនានាបានមកជួបជុំគ្នា<br> | ក្រុមជំនុំនៅកោះហ្វីជី មិនបានធ្វើការរួមគ្នា ឬក៏ជួយគ្នាទេ។ ផ្ទុយទៅវិញ ពួកគេបែរជាប្រកួតប្រជែងជាមួយគ្នា។ ប៉ុន្ដែបន្ទាប់មក ក្រុមជំនុំទាំងនោះបានស្វែងយល់ថា ពួកគេត្រូវតែមកជួបជុំគ្នា ដើម្បីអធិស្ឋានជាមួយគ្នា សម្រាប់ប្រជាជាតិរបស់ពួកគេ។ នៅពេលដែលពួកគេបានរៀបចំកិច្ចប្រជុំជាលើកដំបូង ពួកគេមិនប្រាកដថានឹងមានអ្នកមកចូលរួមឬអត់ទេ ប៉ុន្ដែ បន្ទប់នោះបានពេញទៅដោយអ្នកដឹកនាំក្រុមជំនុំ។ ពួកគេបានបង្កើតកិច្ចសហប្រតិបត្តិការថ្មីដែលហៅថា សមាគមក្រុមជំនុំគ្រិស្ដបរិស័ទ (The Association of Christian Churches)។ គ្រូគង្វាលមួយចំនួនបាននិយាយថា កាលពីអតីតកាល ពួកគេគិតតែពីខ្លួនឯងតែប៉ុណ្ណោះ ប៉ុន្ដែឥឡូវនេះទើបពួកគេដឹងថា ប្រសិនបើពួកគេចង់ឲ្យព្រះជាម្ចាស់ប្រទានពរដល់ប្រជាជាតិរបស់ពួកគេ នោះពួកគេត្រូវធ្វើការរួមគ្នា។ |

| | |
|---|---|
| ៤. នាយករដ្ឋមន្ត្រីស៊ីទី បានសម្តែងការសារភាពកំហុស  | កាលពីខែកក្កដា ឆ្នាំ២០០១ គ្រិស្តបរិស័ទទូទាំងប្រទេស បានមកជួបជុំគ្នា នៅក្នុងការជួបជុំអធិស្ឋាន និងសិក្សាព្រះគម្ពីររួមគ្នា។ នៅចុងបញ្ចប់ លោកនាយករដ្ឋមន្ត្រីស៊ីទីបានចូលរួមអធិស្ឋាន ហើយទូលសុំឲ្យព្រះជាម្ចាស់លើកលែងទោសឲ្យគាត់ និងណែនាំផ្លូវគាត់ ដើម្បីឲ្យគាត់អាចថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់។ មិនយូរប៉ុន្មាន គាត់ក៏បានក្លាយជានាយករដ្ឋមន្ត្រីនៃប្រទេសហ្វីជី និងស្វែងរកអ្នកដឹកនាំដែលគោរពកោតខ្លាចព្រះជាម្ចាស់ ដើម្បីបម្រើប្រទេសជាតិជាមួយគាត់។ |
| ៥. អតីតកាលដ៏ខ្មៅងងឹត  | កាលពីអតីតកាល ប្រទេសហ្វីជីត្រូវបានគេល្បីខាងអំពើអាបធ្មប់ និងការស៊ីសាច់មនុស្ស។ ពួកគេថែមទាំងបានបង្ខំឲ្យជនរងគ្រោះកាប់អុសដើម្បីដុតខ្លួនរបស់ពួកគេផ្ទាល់។ គ្រូអាបធ្មប់នោះអាចដើរនៅលើថ្មក្តៅដោយមិនរលាក។ ប៉ុន្តែអតីតកាលនោះ បានបន្សល់ទុកនូវបណ្តាសានៅក្នុងភូមិទាំងនោះ។ មានមនុស្សស្លាប់ដោយអាថ៌កំបាំង ហើយពួកគេមិនដឹងមកពីមូលហេតុអ្វីនោះទេ។ |
| ៦. រឿងនៅក្នុងភូមិមួយ   | មានភូមិមួយដែលមានភាពល្បីរន្ទឺខាងគ្រឿងញៀនដែលចេះតែកើនឡើង។ មិត្តភក្តិម្នាក់របស់ឈ្មួញជួញដូរគ្រឿងញៀននៅក្នុងតំបន់នោះចាប់ផ្តើមឈឺ។ គាត់ខ្លាចថាគាត់នឹងស្លាប់។ ពួកគេបានឮពីក្រុមជំនុំមួយ ហើយក៏បាននាំគាត់ទៅទទួលការអធិស្ឋាន។ គាត់ក៏បានជា ហើយបានទទួលជឿលើព្រះយេស៊ូ។ នៅពេលដែលមនុស្សនៅក្នុងភូមិបានឮពីអ្វីដែលបានកើតឡើង ពួកគេក៏បានដើរតាមព្រះយេស៊ូ។ ពួកគេចាប់ផ្តើមដឹងថា អារក្សបានកុហកពួកគេ។ ពួកគេក៏ឈប់ធ្វើអំពើអាបធ្មប់នៅតំបន់នោះ។ ឈ្មួញជួញដូរគ្រឿងញៀនបានក្លាយជាគ្រិស្តបរិស័ទ ហើយបានឈប់ជួញដូរគ្រឿងញៀន។ ហើយឥឡូវនេះមាន ៨០% ទៅ៩០%នៃអ្នកភូមិទាំងអស់ជាគ្រិស្តបរិស័ទ។ មេភូមិសប្បាយរីករាយ ប៉ុន្តែវាមិនគ្រប់គ្រាន់នោះទេ។ ពួកគេចាប់ផ្តើមជួបជុំគ្នាអធិស្ឋាននៅម៉ោង៤ព្រឹក។ ពួកគេបានទូលសុំសម្រាប់ការលើកលែងទោស ហើយសុំឲ្យព្រះជាម្ចាស់គ្រប់គ្រងលើសហគមន៍របស់ពួកគេ។ ហើយឥឡូវនេះ មនុស្សដែលតែងតែឈឺនោះ លែងឈឺទៀតហើយ ដើមឈើដែលគ្មានផ្លែ មានផ្លែហើយ ហើយសមុទ្របានចាប់ផ្តើមពោរពេញទៅដោយត្រី ដែលកាលពីអតីតកាលមានត្រីតែបន្តិចបន្តួចប៉ុណ្ណោះ។ |

| | |
|---|---|
| ៧. ការផ្លាស់ប្រែនៅក្នុងពន្ធនាគារ  | អ្នកដែលបានព្យាយាមគ្រប់គ្រងលើរដ្ឋាភិបាល ត្រូវបានចាប់ដាក់ពន្ធនាគារ។ ពន្ធនាគារគឺជាកន្លែងដែលគ្មានសេចក្តីសង្ឃឹម។ ប៉ុន្តែ ក្រុមជំនុំចាប់ផ្តើមនៅក្នុងពន្ធនាគារ។ វាពិតជាពិបាកណាស់កាលពីដំបូង។ មនុស្សស្អប់ពួកគេជាខ្លាំង ហើយចង់សងសឹក។ ពួកគេមិនទាន់ត្រៀមខ្លួនក្នុងការអត់ឱននៅឡើយទេ។ ប៉ុន្តែ ព្រះជាម្ចាស់បានធ្វើឲ្យអ្នកទោសទាំងនោះក្លាយជាគ្រិស្តបរិស័ទ។ សព្វថ្ងៃនេះ អ្នកនឹងឮមនុស្សច្រៀងថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងពន្ធនាគារ។ ប្រសិនបើអ្នកដើរកាត់ពន្ធនាគារ វាឮដូចជាក្រុមជំនុំដែរ។។ |
| ៨. ការផ្លាស់ប្រែជាច្រើនទៀត  | នៅក្នុងទីក្រុងមានការផ្លាស់ប្រែជាច្រើន។ ក្រុមជំនុំនឹងមកជួបជុំគ្នាអធិស្ឋានសម្រាប់ទីក្រុងរបស់ពួកគេ។ ពួកគេបានសុំការលើកលែងទោសរាល់ទង្វើដែលពួកគេបានប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកកាលពីមុន។ ទីក្រុងទាំងនោះចាប់ផ្តើមមានការផ្លាស់ប្រែ។ កាលពីអតីតកាលពួកគេមិនដែលញញឹមទេ ប៉ុន្តែឥឡូវនេះពួកគេញញឹម។ ឧក្រិដ្ឋកម្ម ភាពក្រីក្រ អ្នកសុំទាន ក្មេងតាមចិញ្ចើមផ្លូវត្រូវបានកាត់បន្ថយ។ កុមារត្រូវទៅសាលារៀន។ សេដ្ឋកិច្ចគឺកំពុងតែមានភាពប្រសើរឡើង ហើយភ្ញៀវទេសចរណ៍ក៏បានវិលត្រឡប់មកវិញ។ |
| ៩. រឿងនៅក្នុងភូមិមួយទៀត  | នៅក្នុងតំបន់មួយទៀត គឺគ្មានត្រីអស់រយៈ៥៥ឆ្នាំទៅហើយ ដោយសារតែទឹកត្រូវបានបំពុល និងរងការខូចខាត។ នៅតាមដងទន្លេគ្មានផលដំណាំអ្វីទេ។ ប្រជាជននៅក្នុងភូមិ បានមកជួបជុំគ្នាដើម្បីសារភាពអំពើបាបរបស់បុព្វបុរសពួកគេ និងសារភាពរាល់ទាំងអំពើអាបធ្មប់ទាំងឡាយ។ ពួកគេបានសុំព្រះជាម្ចាស់ឲ្យលើកលែងទោសដល់ពួកគេ។ ពួកគេបានមក ហើយយំសោកអស់រយៈពេលជាច្រើនឆ្នាំ។ មនុស្សគ្រប់គ្នាបានយកវត្ថុតំណាងឲ្យអំពើអាបធ្មប់មក ហើយបំផ្លាញវាចោល។ ជាលទ្ធផល ព្រះជាម្ចាស់បានប្រោសទឹកទន្លេរបស់ពួកគេឲ្យបានជាសះស្បើយ ហើយវាមានពេញទៅដោយត្រី។ ដីនៅតាមដងទន្លេវិញ ក៏ត្រូវបានប្រោសឲ្យបានទៅជាដីឲ្យមានជីជាតិ និងចាប់ផ្តើមផ្តល់ផលដំណាំជាច្រើនដែរ។ |

សូមអានជាមួយគ្នាក្នុង ២របាក្សត្រ ៧៖១៤

- តើមនុស្សបានត្រឡប់មកព្រះជាម្ចាស់ដោយរបៀបណា?
- តើព្រះជាម្ចាស់ប្រោសទឹកដីរបស់ពួកគេឲ្យបានជាដោយរបៀបណា?

តើពួកគេចាប់ផ្តើមស្តាប់បង្គាប់ព្រះជាម្ចាស់តាមរបៀបណា?

ក. ក្រុមជំនុំធ្វើការរួមគ្នា

ខ. ក្រុមជំនុំចាប់ផ្តើមអធិស្ឋានជាមួយគ្នា

គ. មនុស្សបានសុំឲ្យមានការលើកលែងទោសសម្រាប់អ្វីដែលពួកគេបានធ្វើកាលពីអតីតកាល

ឃ. បោះចោលរាល់វត្ថុដែលពាក់ព័ន្ធនឹងអំពើអាបធ្មប់

តើព្រះជាម្ចាស់ប្រទានពរដល់ពួកគេតាមរបៀបណាខ្លះ?

ក. ដីមានដំណាំជាច្រើនបានដុះឡើង ដែលកាលពីមុនគ្មានដំណាំអ្វីទេ

ខ. សមុទ្រមានត្រី

គ. គ្រឿងសមុទ្រគឺធំៗជាងមុន

ឃ. ឧក្រិដ្ឋកម្មត្រូវបានកាត់បន្ថយ

ង. ក្មេងនៅតាមដងផ្លូវមានចំនួនតិចជាងមុន

ច. ប្រជាជនពោរពេញដោយស្នាមញញឹម

ឆ. ភ្ញៀវទេសចរណ៍បានត្រឡប់មកវិញ

ជ. សេដ្ឋកិច្ចកាន់តែប្រសើរឡើង

នៅក្នុងពីរបីមេរៀនបន្ទាប់យើងនឹងមើលបន្ថែមទៀតពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ យើងនឹងមើលពីរបៀបដែលសាតាំងកុហកយើង និងព្យាយាមឲ្យយើងជាប់នៅក្នុងភាពក្រីក្រ។

## ជំពូកទី១ និង ទី២

យើងបានពិភាក្សាពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់មួយចំនួន នៅក្នុងវគ្គបណ្ដុះបណ្ដាលពីមុននេះហើយ។

**នៅក្នុងក្រុមតូច**

នៅក្រោមប្រធានបទនីមួយៗ សូមព្យាយាមចងចាំអំពីអ្វីដែលអ្នកបានរៀនពីប្រធានបទនោះ។ អ្នកអាចគូររូបភាព ឬគិតពីសាច់រឿង ឬក៏ឧទាហរណ៍ពីគំនិតនីមួយៗទាំងនេះ។

- ស្រលាញ់អ្នកជិតខាង
- ការឲ្យ
- ធ្វើការ
- ខាងព្រលឹងវិញ្ញាណ រូបកាយ សង្គម និងសតិបញ្ញា

សូមចែកចាយពីរូបភាពទាំងនេះជាមួយគ្នា។

## ការឆ្លុះបញ្ចាំង

សូមចំណាយពេលពិចារណាលើផ្នែកទាំងអស់នេះ។ តើនឹងអនុវត្តចំណុចទាំងនោះដោយរបៀបណា? តើអ្នកអាចធ្វើអ្វីបានបន្ថែមទៀត?

## មេរៀនទី២

# យើងត្រូវធ្វើជាអ្នកចាត់ចែង ស្នាព្រះហស្តទាំងប៉ុន្មានរបស់ព្រះជាម្ចាស់

**គោលបំណង៖**

១. ដើម្បីយល់ថាយើងត្រូវថែរក្សា និងគ្រប់គ្រងលើស្នាព្រះហស្តរបស់ព្រះជាម្ចាស់ គឺមិនមែន រំលោភបំពាន ឬបណ្តោយឲ្យស្នាព្រះហស្តទាំងនោះគ្រប់គ្រងលើយើងនោះទេ។

២. សូមគិតពីរបៀបដែលពួកគេត្រូវបានគ្រប់គ្រងដោយស្នាព្រះហស្ត និងរបៀបដែលពួកគេអាច បង្ការវាបាន។

៣. សូមគិតពីរបៀបដែលពួកគេមិនបានធ្វើជាអ្នកថែរក្សាការបង្កើតឲ្យបានល្អ និងរបៀបដើម្បីធ្វើឲ្យ កាន់តែប្រសើរឡើង។

**សម្ភារៈដែលត្រូវការ៖**

- កញ្ចប់រូបភាពជំនួយដល់ការសិក្សា — កាតនៃការបង្កើតរបស់ព្រះជាម្ចាស់
- ថង់ដាក់ទឹក
- ក្រណាត់ដើម្បីជូតទឹក
- ផ្ទាំងក្រដាសធំមួយដើម្បីសរសេរផែនការ

## សេចក្តីផ្តើម

យកថង់ទឹកដាក់នៅក្នុងបន្ទប់ នៅលើកន្លែងដែលមិនធ្វើឲ្យប៉ះពាល់ដល់អ្វីមួយឡើយ នៅពេលដែលវា បែកទឹកខ្ចាយ ប៉ុន្តែសិស្សនឹងសម្គាល់ឃើញវា។ ចោះរន្ធតូចមួយនៅក្នុងថង់ ហើយទុកទឹកហូរចេញនៅ ពេលដែលអ្នកចាប់ផ្តើមបង្រៀន។ ត្រូវប្រាកដថារន្ធនោះធំល្មមដើម្បីឲ្យទឹកហូរបានលឿន ដើម្បីឲ្យសិស្ស ចាប់អារម្មណ៍។ ចាប់ផ្តើមបង្រៀន និងបញ្ឈប់ឧទាហរណ៍នោះ នៅពេលដែលមានសិស្សសម្គាល់ឃើញ ទឹកនោះ។

នៅពេលដែលយើងមាននរណាម្នាក់និយាយថាទឹកហូរចេញពីថង់ ហើយប្រាប់ពួកគេថាអ្នកមិនដឹងថាត្រូវធ្វើអ្វីនោះទេ។ អនុញ្ញាតឲ្យសិស្សផ្តល់យោបល់ពីអ្វីដែលអ្នកអាចធ្វើបាន។ ប្រសិនបើគ្មានសិស្សណាម្នាក់ផ្តល់យោបល់អ្វីទេ ចូរសួរពួកគេថា «តើអ្នកអាចធ្វើអ្វីបានខ្លះ?»

**ពិភាក្សានៅក្នុងក្រុមធំ**

- តើមានអ្វីទើបនឹងកើតឡើង?
- តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនបានបញ្ឈប់ទឹកកុំឲ្យហូរ?
- តើអ្នកគិតដូចម្តេច នៅពេលខ្ញុំនិយាយថា «ខ្ញុំមិនដឹងថាត្រូវធ្វើអ្វី» ដើម្បីបញ្ឈប់ទឹកកុំឲ្យហូរ?

ព្រះជាម្ចាស់បានប្រាប់យើងនៅក្នុងជំពូកដំបូងនៃព្រះគម្ពីរថាឲ្យគ្រប់គ្រង ឬធ្វើជា «ចៅហ្វាយ» នៃអ្វីៗដែលទ្រង់បានបង្កើតមក។ នៅក្នុងមេរៀននេះ យើងនឹងពិនិត្យលើព្រះបន្ទូលនេះឲ្យកាន់តែច្បាស់ថែមទៀត។

## ដំណើររឿង

ចូរអាននូវសាច់ខាងក្រោមឲ្យសិស្សរបស់អ្នកស្តាប់

ប្រជាជនឥណ្ឌា ប៉ូកុមឈី (Pokomchi) គឺជាប្រជាជនក្រីក្របំផុតនៅក្នុងខេត្តដែលក្រជាងគេ ដែលមានឈ្មោះថា ក្វាតេម៉ាឡា (G uatemala)។ កាលពីជាង៣០ឆ្នាំមុន មានបេសកជនបានមកផ្សាយដំណឹងល្អ និងដាំក្រុមជំនុំ។ មានប្រជាជនប៉ូកុមឈីជាច្រើនបានទទួលជឿលើព្រះគ្រិស្ត ប៉ុន្តែសហគមន៍របស់ពួកគេនៅតែក្រីក្រដដែល។ ក្រុមយុវវ័យដែលបានក្លាយជាគ្រិស្តបរិស័ទមានសេចក្តីសង្ឃឹមសម្រាប់ពេលអនាគត ប៉ុន្តែមិនមានសេចក្តីសង្ឃឹមសម្រាប់បច្ចុប្បន្ននោះទេ។ តាមការពិត ពួករង់ចាំតែស្លាប់តែប៉ុណ្ណោះ ដើម្បីឲ្យពួកគេអាចចាកចេញពីជីវិតដែលវេទនាលើផែនដីនេះ ដើម្បីទៅរស់នៅជាមួយព្រះយេស៊ូនៅស្ថានសួគ៌។

ការនេះចាប់ផ្តើមផ្លាស់ប្រែនៅពេលដែលមានគ្រូគង្វាលវ័យក្មេងម្នាក់ឈ្មោះ អាធូរ៉ូ (Arturo) ចាប់ផ្តើមធ្វើការក្នុងចំណោមប្រជាជនប៉ូកុមឈី។ គាត់ចាប់ផ្តើមធ្វើការផ្ទាល់ជាមួយគ្រូគង្វាលជនជាតិប៉ូកុមឈីដែលមិនចេះអក្សរ។ គាត់បានបង្រៀនព្រះគម្ពីរដល់ពួកគេយ៉ាងប្រុងប្រយ័ត្ន។ នៅពេលដែលពួកគេកំពុងរៀននោះ គាត់បានពន្យល់ពីរបៀបដែលព្រះជាម្ចាស់ចង់ឲ្យយើងអនុវត្តគោលការណ៍ និងក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរក្នុងជីវិតរស់នៅសព្វថ្ងៃរបស់យើង។

បញ្ហាចម្បងមួយចំពោះប្រជាជនប៉ូកុមឈី នោះគឺខ្វះខាតកន្លែងផ្ទុកផលដំណាំឲ្យបានត្រឹមត្រូវ។ ជាញឹកញាប់កសិករប្រមូលផលដំណាំល្អៗតែប៉ុណ្ណោះ ប៉ុន្តែកណ្តុរស៊ីផលដំណាំអស់ មុនពេលកូនៗរបស់ពួកគេ

អាចបរិភោគបាន។ លោកអាផ្សូ បានសួរទៅកសិករថា «រវាងអ្នក និងកណ្ដុរ តើមួយណាឆ្លាតជាង?» កសិករនាំគ្នាសើច ហើយនិយាយថា គឺ «កណ្ដុរ»។ លោកអាផ្សូ សួរទៀតថា «តើអ្នកមានអំណាចលើកណ្ដុរ ឬក៏កណ្ដុរមានអំណាចលើជីវិតអ្នក?» ពួកកសិករនាំគ្នាយល់ស្របថា កណ្ដុរមានអំណាចលើពួកគេ និងក្រុមគ្រួសាររបស់ពួកគេ។ កណ្ដុរវាស៊ីស្បៀងអស់ ហើយគ្មាននរណាអាចបញ្ឈប់វាបាននោះទេ។ គឺកណ្ដុរ មិនមែនមនុស្សទេ ដែលសម្រេចថាកណ្ដុរអាចស៊ីអ្វីបាន។



បន្ទាប់មកលោកអាផ្សូ បានបង្ហាញពួកគេនៅក្នុងព្រះគម្ពីរថា ទាំងបុរសនិងស្ត្រីគឺមានអំណាចលើអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក។ គាត់បានរំឭកពួកគេថា ព្រះជាម្ចាស់បានប្រទានពរដល់ពួកគេជាមួយនឹងភាពច្នៃប្រឌិត ដោយសារតែទ្រង់បានបង្កើតពួកគេមកឲ្យមានលក្ខណៈដូចព្រះអង្គ។ ពួកគេបានប្រើភាពច្នៃប្រឌិតដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេ ដើម្បីគោរពនិងប្រតិបត្តិតាមគោលការណ៍នៃការមានអំណាចលើអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក និងមិនអនុញ្ញាតឲ្យអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក មានអំណាចលើពួកគេឡើយ។

ប្រជាជនប៉ូកុមឈើ បានសម្រេចថាពួកគេត្រូវធ្វើសកម្មភាពដោយយោងតាមព្រះគម្ពីរ ដើម្បីមានអំណាចលើកណ្ដុរ។ ពួកគេចាប់ផ្ដើមសាងសង់កន្លែងផ្ទុកស្បៀងរបស់ពួកគេ ដែលមិនឲ្យកណ្ដុរចូលទៅស៊ីស្បៀងអាហាររបស់ពួកគេទេ។ នៅពេលដែលស្បៀងអាហារត្រូវបានការពារពីកណ្ដុរ ពួកគេក៏ចាប់ផ្ដើមមានអាហារគ្រប់គ្រាន់សម្រាប់ក្រុមគ្រួសាររបស់ពួកគេ។

**ពិភាក្សានៅក្នុងក្រុមធំ**

- តើមានអ្វីបានកើតឡើងនៅក្នុងរឿងនេះ?
- តើយើងអាចរៀនពីអ្វីបានខ្លះ តាមរយៈសាច់រឿងនេះ? តើអ្នកអាចអនុវត្តវានៅក្នុងតំបន់របស់យើងដោយរបៀបណា?

## ការសិក្សាព្រះគម្ពីរ

ចូរអានលោកុប្បត្តិ ១៖២៦-២៨, លោកុប្បត្តិ ២៖១៥, ទំនុកតម្កើង ២៤៖១

- តើផែនដីជាកម្មសិទ្ធិរបស់នរណា? (ទំនុកតម្កើង ២៤)

- តើព្រះជាម្ចាស់បានប្រាប់ឲ្យមនុស្សធ្វើអ្វីជាមួយនឹងស្នាព្រះហស្តដែលទ្រង់បានបង្កើតមក?
    - មានអំណាចលើវា
    - ធ្វើការលើវា
    - មើលថែរក្សាវា
- តើការ **ថែរក្សា** វា មានអត្ថន័យដូចម្តេច? តើយើងធ្វើអ្វី នៅពេលដែលយើងថែរក្សាអ្វីមួយ? តើយើងអាចថែរក្សាស្នាព្រះហស្តរបស់ព្រះជាម្ចាស់បានដោយរបៀបណា?
    - នៅពេលដែលយើងថែរក្សាអ្វីមួយនោះ គឺយើងការពារវា និងត្រូវប្រាកដថាវាមិនបែកបាក់ ឬក៏ត្រូវបានបំផ្លាញ។ យើងអាចធ្វើដូចនេះបាន ដោយមិនអនុញ្ញាតឲ្យស្នាព្រះហស្តទ្រង់ត្រូវបានបំផ្លាញ។ យើងត្រូវតែប្រុងប្រយ័ត្នពីកិច្ចការដូចជា ការកាប់ដើមឈើច្រើនពេក ដែលអាចបង្កឲ្យមានការបាក់ដី។
- តើការ**ធ្វើការ**លើវាមានអត្ថន័យដូចម្តេច? តើយើងអាចធ្វើដូច្នោះបានដោយរបៀបណា?
    - នៅពេលដែលយើងធ្វើការលើវា គឺយើងធ្វើឲ្យមានផលិតផលអ្វីមួយ។ ស្នាព្រះហស្តដែលព្រះជាម្ចាស់បានបង្កើតមក គួរតែផ្តល់អាហារ សម្រស់ និងបំពេញតម្រូវការដទៃទៀត ឧទាហរណ៍៖ សម្ភារៈសម្រាប់គេហដ្ឋាន។ នៅពេលដែលយើងធ្វើកសិកម្ម គឺយើងកំពុងតែធ្វើនូវអ្វីដែលព្រះជាម្ចាស់បញ្ជាឲ្យយើងធ្វើ។ យើងគួរតែរីករាយនៅពេលដែលយើងធ្វើកសិកម្ម ដោយសារតែយើងគោរពតាមបទបញ្ជារបស់ទ្រង់។
- តើការមាន**អំណាច**លើអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមានអត្ថន័យដូចម្តេច? (សូមគិតពីសាច់រឿងរបស់ប្រជាជនប៉ូកុមឈី)
    - ការដែលមានអំណាចមានន័យថា យើងអាចគ្រប់គ្រងលើអ្វីមួយ។ ឧទាហរណ៍ស្តីអំពីថង់ទឹក គឺយើងអាចគ្រប់គ្រងលើលំហូរទឹក ដោយវាមិនគ្រប់គ្រងលើយើងនោះទេ។ ឧទាហរណ៍៖  ស្ពានគ្រប់គ្រងលើស្នាព្រះហស្តដែលព្រះជាម្ចាស់បានបង្កើត។ ប្រសិនបើគ្មានស្ពាននោះទេ ទឹកទន្លេនឹងកំណត់ពីកន្លែងដែលយើងអាចទៅបាន។ បើមានស្ពាន ឬទូក គឺយើងអាចសម្រេចពីកន្លែងដែលយើងចង់ទៅ។ វាមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ដែលយើងមានអារម្មណ៍ថាយើងត្រូវបានគ្រប់គ្រងដោយស្នាព្រះហស្តរបស់ទ្រង់។ យើងត្រូវតែសុំព្រះជាម្ចាស់ឲ្យបន្តប្រទានឲ្យយើងនូវគំនិតច្នៃប្រឌិតដើម្បីគ្រប់គ្រងលើការបង្កើត។

នៅពេលដែលយើងគ្រប់គ្រង ធ្វើការ និងថែរក្សាលើការបង្កើត គឺយើងកំពុងតែគោរពតាមបទបញ្ជារបស់ព្រះជាម្ចាស់។ យើងអាចហៅវាថា មានទំនាក់ទំនងត្រឹមត្រូវជាមួយការបង្កើត។ ជាអកុសល ដោយសារ

តែអំពើបាប វាកាន់តែពិបាកនៅពេលដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើងដំបូង នូវបទបញ្ញារបស់ទ្រង់ ប៉ុន្តែទ្រង់នៅតែចង់ឲ្យយើងគោរពវា។

## ទំនាក់ទំនងត្រឹមត្រូវជាមួយស្នាព្រះហស្តដែលព្រះជាម្ចាស់បានបង្កើតមក

សូមបំបែកជា ២ ឬ ៣ ក្រុមតូចៗ។ សូមចែកឲ្យក្រុមនីមួយនូវកញ្ចប់រូបភាពនៃការបង្កើត ដែលដកចេញពីរូបភាពជំនួយដល់ការសិក្សា។ សុំឲ្យពួកគេមើលរូបភាពលើកាតនីមួយៗ។ រៀបវាជាជុំៗ យោងតាមការបង្ហាញពីទំនាក់ទំនងត្រឹមត្រូវជាមួយស្នាព្រះហស្តរបស់ព្រះជាម្ចាស់ឬអត់។

សូមចែកកាតទទេមួយចំនួនទៅដល់ពួកគេ។ សុំឲ្យពួកគេគូរនូវឧទាហរណ៍បន្ថែមទៀតនៃទំនាក់ទំនងនីមួយៗពីសហគមន៍របស់ពួកគាត់។

នៅពេលដែលពួកគេបញ្ចប់ការងារនៅក្នុងក្រុម សូមមើលកាតម្តងមួយៗ។ នៅក្នុងកាតនីមួយៗសូមសួរថា តើយើងធ្វើបែបនេះនៅក្នុងសហគមន៍យើងដែរឬទេ។ សម្រាប់កាតដែលល្អ សូមសួរថាយើងគួរតែធ្វើបែបនេះឲ្យបានច្រើនដែរឬទេ ហើយសម្រាប់កាតដែលមិនល្អវិញ សូមសួរថា តើយើងគួរតែឈប់ធ្វើបែបនេះដែរឬទេ។ តើយើងអាចធ្វើការផ្លាស់ប្តូរទាំងនេះ ដោយរបៀបណាខ្លះ?

ចូរសុំឲ្យសិស្សជ្រើសរើសគំនិតពីរបី ហើយគិតពីរបៀបដែលយើងអាចធ្វើកិច្ចការទាំងនេះ ដោយទង្វើនៃសេចក្តីស្រលាញ់។

# ភាគរូបភាពពីស្ទាព្រះហស្ដដែលព្រះជាម្ចាស់បានបង្កើត

| | | |
|---|---|---|
| **ថៃទាំសត្វ (ចិញ្ចឹមសត្វ)**<br> | **ទឹកស្អាត**<br> | **ដាំដំណាំ**<br> |
| ☺ ព្រះជាម្ចាស់បានប្រាប់យើងឲ្យមើលថៃទាំសត្វ។ យើងត្រូវតែឲ្យពួកវាមានទ្រុងសមស្រប ដូច្នេះពួកវានឹងមិននាំយកជំងឺមកក្នុងផ្ទះរបស់យើងឡើយ។ នេះជាផ្នែកនៃការគ្រប់គ្រងលើស្នាព្រះហស្ដដែលព្រះជាម្ចាស់បានបង្កើត។ | ☺ ជីកអណ្ដូង និងប្រើប្រាស់ធុងចម្រោះទឹក ដាំទឹក ឬដាក់វាហាលថ្ងៃ (SODIS) ដើម្បីទទួលបានទឹកស្អាតសម្រាប់សារពាង្គកាយរបស់យើង ដើម្បីពិសា និងមិនធ្វើឲ្យយើងឈឺ។ | ☺ យើងត្រូវតែដាំដំណាំសម្រាប់តម្រូវការរបស់យើង។ នេះជាផ្នែកមួយដែលយើងធ្វើការនៅលើដី។ ការដាំដំណាំ គឺជាវិធីសាស្ត្រមួយដើម្បីឲ្យគ្រួសារមានអាហារដែលមានជីវជាតិ។ |
| **ការធ្វើកសិកម្ម**<br> | **សង់ផ្ទះ**<br> | **បង្គន់**<br> |
| ☺ យើងចាំបាច់ត្រូវធ្វើកសិកម្មនៅលើដីដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។ វាគួរតែផ្គត់ផ្គង់ដល់គ្រួសាររបស់យើង មិនមែនគ្រប់គ្រងលើយើងនោះទេ។ យើងត្រូវបង្កើតប្រព័ន្ធធារាសាស្ត្រដើម្បីធ្វើឲ្យដីមានកាន់តែមានជីវជាតិ និងបង្កើតផលបានច្រើន។ | ☺ យើងត្រូវការជម្រក ពីកំដៅថ្ងៃ និងភ្លៀង។ ត្រូវប្រាកដថាយើងមានផ្ទះដែលមានសុវត្ថិភាព និងជាផ្នែកនៃការគ្រប់គ្រងលើស្នាព្រះហស្ដដែលព្រះជាម្ចាស់បានបង្កើត។ នោះយើងនឹងលែងគ្រប់គ្រងដោយព្រះអាទិត្យ និងភ្លៀងទៀតហើយ។ | ☺ បង្គន់ជួយកាត់បន្ថយជំងឺ និងរក្សាបរិស្ថានរបស់យើងឲ្យបានស្អាត។ យើងត្រូវតែថៃរក្សាបរិស្ថានរបស់យើង និងត្រូវប្រាកដថាវាមិនបង្កឲ្យយើងមានជំងឺ។ |

| ការនេសាទ | កាប់ដើមឈើ | អន្ទាក់ចាប់កណ្ដុរ |
| --- | --- | --- |
|  |  |  |
| ☺ ការនេសាទគឺជាវិធីមួយដែលយើងអាចផ្គត់ផ្គង់អាហារដល់ក្រុមគ្រួសារ។ | ☹ យើងត្រូវតែប្រុងប្រយ័ត្ន នៅពេលដែលយើងកាប់ដើមឈើ យើងគួរតែដាំដើមឈើថ្មី។ ដើមឈើគឺជាអំណោយដែលមកពីព្រះជាម្ចាស់ ដែលការពារការបាក់ដី។ ប្រសិនបើកាប់ដើមឈើ ហើយមិនមិនប្រើដីនោះ វានឹងឆាប់ក្លាយជាដីដែលគ្មានជីវជាតិ និងមិនផ្ដល់ផលអ្វីឡើយ។ | ☺ អន្ទាក់ចាប់កណ្ដុរ អាចជួយយើងកាត់បន្ថយកណ្ដុរដែលស៊ីអាហាររបស់យើង។ អន្ទាក់កណ្ដុរមិនចាំបាច់ស្មុគស្មាញពេកទេ។ យើងអាចធ្វើពីឫស្សីដូចជាអន្ទាក់កណ្ដុរទាំងនេះ។ យើងត្រូវតែគ្រប់គ្រងលើអ្វីដែលព្រះជាម្ចាស់បានបង្កើត និងមិនឲ្យកណ្ដុរធ្វើឲ្យយើងឈឺឡើយ។ |
| **អន្ទាក់ចាប់រុយ** | **គ្របម្ហូបអាហារដើម្បីការពាររុយ** | **ដេកនៅក្នុងមុង** |
|  |  |  |
| ☺ អន្ទាក់ចាប់រុយ គឺជាវិធីសាស្ត្រមួយដើម្បីកាត់បន្ថយរុយ។ ព្រះបានប្រាប់យើងឲ្យគ្រប់គ្រងលើអ្វីដែលទ្រង់បានបង្កើត ហើយការកាត់បន្ថយចំនួនរុយ គឺជាវិធីសាស្ត្រមួយដែលយើងអាចធ្វើបែបនោះបាន។ | ☺ យើងត្រូវតែការពារក្រុមគ្រួសាររបស់យើងពីជំងឺផ្សេងៗ ដែលចម្លងតាមរយៈរុយ ដោយគ្របម្ហូបអាហាររបស់យើង។ | ☺ ការដេកនៅក្នុងមុងជួយយើងមិនឲ្យកើតជំងឺគ្រុនចាញ់ ឬជំងឺផ្សេងៗដែលចម្លងដោយមូស។ |

| | | |
|---|---|---|
| **ការពង្រាយសំរាម**<br> | **ដីស្ងួត/ ដីគ្មានជីវជាតិ**<br> | **ជីកអណ្តូង**<br> |
| ☹ ព្រះជាម្ចាស់បានសុំឲ្យយើងថែរក្សាបរិស្ថានរបស់យើង។ នេះមានន័យថាយើងគួរតែថែរក្សាវាឲ្យបានស្អាតដើម្បីថ្វាយកិត្តិយសដល់ព្រះជាម្ចាស់។ យើងមិនគួរចោលសំរាមលើដីនោះទេ ប៉ុន្តែគួរតែដាក់សំរាមនៅក្នុងធុងសំរាម។ | ☹ យើងត្រូវតែស្វែងរកវិធីសាស្ត្រដើម្បីប្រែដីដែលគ្មានជីជាតិ ទៅជាដីដែលមានជីជាតិវិញ ដោយវិធីសាស្ត្រដូចជា ប្រព័ន្ធធារាសាស្ត្រ ឬ ជីធម្មជាតិ។ | ☺ អណ្តូងគឺវិធីសាស្ត្រមួយដើម្បីទទួលបានទឹកនៅក្រោមដី ដែលព្រះជាម្ចាស់បានផ្តល់ឲ្យ។ ទឹកអណ្តូងជួយយើងឲ្យរស់នៅស្អាត និងមានសុខភាពល្អ។ |
| **ដាំបន្លែ**<br> | **ចិញ្ចឹមសត្វនៅផ្ទះ**<br> | **កណ្តុរស៊ីម្ហូប**<br> |
| ☺ ការដាំបន្លែគឺរបៀបមួយដែលយើងអាចផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់យើង។ | ☹ សត្វចិញ្ចឹមមិនគួរនៅជិតអាហាររបស់យើងនោះទេ។ ពួកវានាំជំងឺមក។ យើងត្រូវតែគ្រប់គ្រងសត្វរបស់យើង និងធ្វើទ្រុងឲ្យវា។ | ☹ កណ្តុរនាំជំងឺមក ហើយវាស៊ីអាហារដែលយើងត្រូវការ។ យើងត្រូវតែការពារអាហាររបស់យើងពីកណ្តុរ ហើយប្រើអន្ទាក់ដើម្បីព្យាយាមកាត់បន្ថយកណ្តុរនៅក្នុងតំបន់របស់យើង។ |

## មេរៀនទី៣

# យើងអាចផ្លាស់ប្រែអនាគតរបស់យើង

**គោលបំណង៖**

១. យល់ថាគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់យើងមិនដែលផ្លាស់ប្រែនោះទេ។ ទ្រង់មានគោលបំណងសម្រាប់ជីវិតរបស់យើង និងចង់ឲ្យយើងជីវិតរបស់យើងកាន់តែរីកចម្រើនឡើង និងកាន់តែប្រសើរឡើង។

២. យល់ពីរបៀបដែលយើងជាមនុស្សដែលនាំការផ្លាស់ប្រែដល់អ្នកដទៃ

**សម្ភារៈត្រូវការ**

- កញ្ចប់រូបភាពជំនួយដល់ការសិក្សា — រូបភាពគ្រួសារដែលមានទុក្ខលំបាក
- កញ្ចប់រូបភាពជំនួយដល់ការសិក្សា — កាតរូបភាពនិយាយពីព្រះយេស៊ូ និងពិធីបុណ្យសព
- កញ្ចប់រូបភាពជំនួយដល់ការសិក្សា — ការរូបភាពសម្រាប់អ្នកនាង លី (Lee)
- មេរៀនរបស់សិស្ស

## សេចក្តីផ្តើម



បង្ហាញរូបភាពនៃក្រុមគ្រួសារមួយដែលជួបទុក្ខលំបាក

សួរទៅសិស្ស៖

- តើអ្នកគិតថាក្រុមគ្រួសារនេះ បានផ្លាស់ប្រែដែរឬទេនៅក្នុងរយៈពេល៦ខែកន្លងមកនេះ?
- តើអ្នកគិតថាក្រុមគ្រួសារនេះនឹងផ្លាស់ប្រែនៅខែក្រោយដែរឬទេ?
- តើអ្នកគិតថាក្រុមគ្រួសារនេះនឹងផ្លាស់ប្រែនៅរយៈពេល៦ខែបន្ទាប់ទេ?
- តើអ្នកគិតថាក្រុមគ្រួសារនេះនឹងផ្លាស់ប្រែនៅឆ្នាំក្រោយដែរឬទេ?

ប្រសិនបើពួកគេឆ្លើយថា**ទេ** ចំពោះសំណួរទាំងនេះ ចូរសួរពួកគេថាហេតុអ្វី? ប្រសិនបើពួកគេឆ្លើយថា បាទ/ចាស៎ រួចសួរពួកគេថា តើការផ្លាស់ប្រែនេះនឹងកើតឡើងដោយរបៀបណា?

សូមអានខគម្ពីរនៅក្នុងមេរៀនទី១ម្តងទៀត - ទុតិយកថា ២៨៖១-១៤

- តើព្រះជាម្ចាស់ចង់ប្រទានពរដល់យើងដោយរបៀបណា?
- តើខគម្ពីរទាំងនេះ ឆ្លើយតបចំពោះគ្រួសារនេះដែរឬទេ?

ចូរអាននៅក្នុង យេរេមា ២៩៖១១

- តើព្រះជាម្ចាស់មានផែនការប្រភេទណាសម្រាប់ជីវិតរបស់យើង?
- តើខគម្ពីរទាំងនេះអាចឆ្លើយតបចំពោះគ្រួសារនេះដែរឬទេ? ហេតុអ្វី?

**នៅក្នុងក្រុមតូច**

គូររូបមួយទៀតនៃគ្រួសារនេះ តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ។

## ការបង្កើតឲ្យមានការផ្លាស់ប្រែ

«កូនរបស់ស្តេច នឹងក្លាយជាស្តេច ហើយកូនរបស់សង្ឃ នឹងក្លាយជាសង្ឃ»

«ទន្លេមានពេលដែលវាតូចចង្អៀត ហើយក៏មានពេលដែលវាធំទូលាយ រីឯជីវិតរបស់មនុស្សក៏ដូចគ្នាដែរ។»

«ដើម្បីមានអាហារបរិភោគគ្រប់គ្រាន់ជាការពិបាក ប៉ុន្តែក្លាយជាអ្នកមានជាការងាយស្រួល។»

ទាំងនេះគឺពាក្យស្លោកទូទៅ អ្នកនឹងចង់ជ្រើសរើសពាក្យស្លោកមួយដែលស័ក្តិសមសម្រាប់ប្រទេសរបស់អ្នក។

- តើពាក្យស្លោកទាំងនេះមានអត្ថន័យដូចម្តេច?
- តើអ្នកមានដឹងពីពាក្យស្លោកផ្សេង ដែលមានអត្ថន័យស្រដៀងគ្នាដែរឬទេ?
- តើអ្នកយល់ស្របនឹងពាក្យស្លោកមួយណា?
- តើពាក្យស្លោកមួយណា (ប្រសិនបើមាន) ដែលត្រឹមត្រូវតាមព្រះគម្ពីរ?

យេរេមា ៥៖១

- តើមានមនុស្សប៉ុន្មាននាក់ដែលព្រះជាម្ចាស់កំពុងតែស្វែងរក?
- តើនឹងមានអ្វីកើតឡើងប្រសិនបើទ្រង់រកឃើញមនុស្សម្នាក់នោះ?

អេសេគាល ២២៖៣០

- តើមានមនុស្សប៉ុន្មាននាក់ដែលព្រះជាម្ចាស់កំពុងតែស្វែងរក?
- តើនឹងមានអ្វីកើតឡើងប្រសិនបើទ្រង់រកឃើញមនុស្សម្នាក់នោះ?
- តើនឹងមានអ្វីកើតឡើងប្រសិនបើទ្រង់រកមិនឃើញមនុស្សម្នាក់នោះ?

រំឭកទៅកាន់សិស្សថា សូម្បីមនុស្សតែម្នាក់ដែលដើរតាមទ្រង់យ៉ាងស្មោះទ្រង់ អាចជួយសង្គ្រោះទីក្រុងទាំងមូលពីការបំផ្លិចបំផ្លាញបាន។

# ធ្វើជាមនុស្សដែលនាំការផ្លាស់ប្រែ

សូមអាននៅក្នុងលូកា ៧៖១១-១៧

រឿងនេះបានកើតឡើងនៅពេលដែលព្រះយេស៊ូ និងសិស្សរបស់ទ្រង់បានជួបស្ត្រីមេម៉ាយម្នាក់នៅក្នុងពិធីបុណ្យសពរបស់កូនប្រុសនាង ខណៈពេលដែលពួកគេបានឆ្លងកាត់ទ្វារកំពែងក្រុង។ សិស្សរបស់ព្រះយេស៊ូមានក្តីរំភើប ដោយសារតែពួកគេបានឃើញការអស្ចារ្យមួយ។ ស្ត្រីមេម៉ាយ និងមនុស្សនៅក្នុងពិធីបុណ្យសពកំពុងតែយំសោក។

- តើមានអ្វីបានកើតឡើងនៅក្នុងរឿងនេះ?

ប្រើកាតនៅក្នុងកញ្ចប់រូបភាពជំនួយដល់ការសិក្សា ដើម្បីពិនិត្យមើលចំណុចទាំង៨នេះ ដែលយើងអាចរៀនពីសាច់រឿងនេះ ពីមនុស្សម្នាក់ដែលនាំការផ្លាស់ប្រែ។

១. **ព្រះយេស៊ូបានកត់សម្គាល់លើនាង។** មានមនុស្សជាច្រើននៅក្នុងចំណោមហ្វូងមនុស្ស។ សិស្សរបស់ព្រះយេស៊ូពិតជាភ្ញាក់ផ្អើល ពីការអស្ចារ្យដែលពួកគេបានឃើញ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះយេស៊ូបានសម្គាល់នាងនៅក្នុងកណ្តាលចំណោមហ្វូងមនុស្ស។ ប្រសិនបើយើងធ្វើជាមនុស្ស ដែលនាំយកការផ្លាស់ប្រែ យើងត្រូវតែធ្វើជាមនុស្សដែលសម្គាល់ពីអ្នកដទៃ។ យើងត្រូវប្រាកដថា យើងឃើញបុគ្គលម្នាក់ៗ មិនមែនតែហ្វូងមនុស្សប៉ុណ្ណោះទេ។

២. **«ទ្រង់មានព្រះហឫទ័យអាណិតអាសូរដល់នាង»។** ប្រសិនបើចង់នាំមកនូវការផ្លាស់ប្រែ យើងត្រូវតែមានចិត្តអាណិតអាសូរ។ យើងត្រូវតែធ្វើមនុស្សដែលមានចិត្តទន់ នៅពេលយើងឃើញពីតម្រូវការរបស់មនុស្ស។ មានពេលជាច្រើនដែលយើងលែងមើលឃើញ និងលែងខ្វល់ខ្វាយពីអ្នកដទៃ។ តើយើងនឹងធ្វើអ្វីនៅពេលដែលយើងឃើញជនក្រីក្រម្នាក់នៅក្នុងសហគមន៍របស់យើង? តើយើងនឹងធ្វើអ្វី នៅពេលដែលយើងឃើញម្តាយដែលប្តីរបស់គាត់បានចាកចោលគ្រួសារ ឬទុកឲ្យជីដូនជីតាជាអ្នកមើលថែកូនតូចៗ? តើយើងមានអារម្មណ៍អាណិតអាសូរដែរឬទេ? ចូរទូលសុំឲ្យព្រះជាម្ចាស់ប្រទានឲ្យអ្នកនូវសេចក្តីស្រលាញ់ សម្រាប់សហគមន៍របស់អ្នក។ ចូរសុំឲ្យទ្រង់បង្ហាញអ្នកពីមនុស្សនៅក្នុងសហគមន៍ ដូចដែលទ្រង់បានទតឃើញពួកគេ។

៣. **ទ្រង់ប្រទាននូវពាក្យដែលលើកទឹកចិត្ត។** ជាញឹកញាប់មនុស្សត្រូវការនរណាម្នាក់ដើម្បីថែទាំ និងលើកទឹកចិត្តពួកគេ។ វាជាការងាយស្រួលដែលគិតថា យើងត្រូវការធនធានដើម្បីជួយមនុស្ស ប៉ុន្តែជារឿយៗមនុស្សដែលត្រូវការជំនួយពិតប្រាកដនោះ គឺពិតជាត្រូវការនរណាម្នាក់ដើម្បីនៅជាមួយពួកគេ និងលើកទឹកចិត្តដល់ពួកគេ។

៤. **ព្រះយេស៊ូបានពាល់មឈូស។** នៅពេលដែលព្រះយេស៊ូបានធ្វើបែបនេះ គឺទ្រង់បានធ្វើខុសនឹងវប្បធម៌របស់ទ្រង់។ សាសន៍យូដាជឿថា អ្នកមិនត្រូវប៉ះពាល់មឈូសនោះទេ បើពុំដូច្នោះទេ អ្នកនឹងក្លាយជាមនុស្សមិនបរិសុទ្ធ។ ព្រះយេស៊ូសុខចិត្តក្លាយជាមនុស្សមិនបរិសុទ្ធ ដើម្បីជួយមនុស្សម្នាក់។ យើងត្រូវតែមានបំណងទទួលយកហានិភ័យ និងភាពកខ្វក់ដើម្បីជួយមនុស្ស។ មនុស្សប្រហែលជានឹងនិយាយពីយើង ឬមិនយល់ស្រប ប៉ុន្តែយើងត្រូវតែធ្វើអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យយើងធ្វើ។

៥. **ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសេចក្ដីអធិស្ឋានគឺពិតជាមានអំណាច។** នៅពេលដែលព្រះយេស៊ូបានអធិស្ឋាន មនុស្សក៏បានរស់ឡើងវិញពីសេចក្ដីស្លាប់។ មិនត្រូវភ្លេចអធិស្ឋាន ចំពោះស្ថានភាពដែលអ្នកប្រឈមមុខនោះទេ។ ត្រូវចំណាយពេលអធិស្ឋានឲ្យមនុស្ស។ ត្រូវតែជឿថាព្រះជាម្ចាស់អាចផ្លាស់ប្រែស្ថានការណ៍ និងយកចិត្តទុកដាក់ពីតម្រូវការផ្សេងៗ។ សូមបង្រៀនមនុស្សឲ្យចេះអធិស្ឋាន ដើម្បីពួកគេអាចស្គាល់ពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

៦. **ទទួលបានលទ្ធផល។** ក្មេងប្រុសនោះបានរស់ពីសេចក្ដីស្លាប់។ យើងគួរតែទទួលបានលទ្ធផលពីកិច្ចការរបស់យើង។ ប្រសិនបើអ្នកចង់ជួយ ចូរចាប់ផ្ដើមពីអ្វីដែលតូច ហើយអ្នកអាចធ្វើបានយ៉ាងងាយស្រួល។ នៅពេលដែលអ្នកទទួលបានជោគជ័យ មនុស្សនឹងរំភើប ហើយមានមនុស្សបន្ថែមទៀតចង់រួមចំណែកក្នុងកិច្ចការនោះដែរ។ ទីបំផុតអ្នកនឹងអាចធ្វើកិច្ចការដែលលំបាកបន្ថែមទៀត។

៧. **ព្រះយេស៊ូបានប្រគល់កូននោះឲ្យទៅម្ដាយរបស់គេវិញ ហើយក៏បានចាកចេញទៅ។** ស្ត្រីជាម្ដាយគឺជាវីរនារីម្នាក់ នាងកំពុងតែធ្វើការអធិប្បាយទាំងអស់។ នាងជាមនុស្សសំខាន់ម្នាក់។ នៅពេលដែលយើងជួយមនុស្ស យើងត្រូវតែប្រាកដថាយើងមិនព្យាយាមធ្វើវាដើម្បីបានមុខមាត់ ឬទាក់ទាញចំណាប់អារម្មណ៍នោះទេ។ ចូរអនុញ្ញាតឲ្យមនុស្សម្នាក់នោះបញ្ចេញពន្លឺ នៅពេលដែលពួកគេប្រាប់អ្នកដទៃនូវអ្វីដែលបានកើតឡើង។ វានឹងកសាងសេចក្ដីថ្លៃថ្នូររបស់ពួកគេ ជាជាងអ្នកទទួលយកប្រយោជន៍ទាំងអស់។

៨. **ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។** នៅចុងបញ្ចប់សិរីរុងរឿងនឹងត្រឡប់ទៅព្រះជាម្ចាស់វិញ។ ត្រូវប្រាកដថានៅពេលដែលអ្វីៗត្រូវបានបញ្ចប់ គឺព្រះជាម្ចាស់ជាព្រះដែលទទួលបានការកោតសរសើរ។

**រំឭកពីរឿងរបស់អ្នកស្រី លី ពីមេរៀនទី១**

អ្នកស្រីលី គឺជាស្ត្រី (តួអង្គពិត) ម្នាក់ដែលរស់នៅតាមបណ្តោយទន្លេមេគង្គ។ នាងមានចិត្តចង់ជួយគ្រួសារក្រីក្រនៅក្នុងសហគមន៍របស់នាង ជាពិសេសអ្នកដែលគ្មានការងារធ្វើ។ នាងចាប់ផ្តើមសួរសុខទុក្ខគ្រួសារមួយចំនួនជារៀងរាល់ខែ ដើម្បីជួយជីវភាពរស់នៅរបស់ពួកគេ។ ខាងក្រោមនេះជាសាច់រឿង៣ ដែលនិយាយពីរបៀបដែលនាងបានជួយគ្រួសារទាំងនោះ។ រឿងទាំងនេះគឺសុទ្ធតែជារឿងពិត។

**រឿងទី១៖ អ្នកស្រីលី និងសួនផ្កា**



នៅក្នុងតំបន់របស់នាង មានក្រុមគ្រួសារមួយដែលមានកូនពីរនាក់។ ឪពុកម្តាយរបស់ពួកគេ គ្មានការងារធ្វើនោះទេ។ អ្នកស្រីលី បានមកសួរសុខទុក្ខពួកគេ ហើយបានសម្គាល់ថាមានដីមួយកន្លែង ដែលនៅមុខផ្ទះរបស់ពួកគេ។ នាងបានសួរថា «ហេតុអ្វីបានជាអ្នកមិនដាំផ្កា? អ្នកអាចធ្វើឲ្យផ្ទះរបស់អ្នកស្អាត និងអាចលក់ផ្កានៅផ្សារជិតនេះបាន។»

ស្ត្រីជាម្តាយក៏បានធ្វើតាមនាង ហើយចាប់ផ្តើមយកផ្កាដែលគាត់បានដាំ ទៅលក់នៅឯផ្សារ។ ប៉ុន្តែ មិនយូរប៉ុន្មាន អ្នកទិញក៏បានសួររកផ្កាប្រភេទផ្សេងដែរ ប៉ុន្តែដោយសារតែនាងមានដីតែមួយតូច មិនអាចដាំប្រភេទផ្កាផ្សេងបាននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីជាម្តាយបានទិញផ្កាពីអ្នកដាំផ្សេង ហើយយកមកលក់ជាមួយផ្ការបស់នាង ដើម្បីទទួលបានចំណូល។ ឥឡូវនេះ នាងមានតូបតូចមួយនៅក្នុងផ្សារដើម្បីលក់ផ្កា ហើយនាងគិតថា «ខ្ញុំអាចលក់របស់ផ្សេងទៀតបានតើ!» នាងក៏បានក្រោកពីព្រលឹមដើម្បីទៅទិញចេក និងដូងដើម្បីយកមកលក់នៅផ្សារ ក្នុងតូបលក់ផ្ការបស់នាង។

**រឿងទី២៖ អ្នកស្រីលី និងដំលូងជ្វា**

មានគ្រួសារមួយទៀតដែលត្រូវការជំនួយ ចង់បានការងារធ្វើ ប៉ុន្តែមិនដឹងថាធ្វើអ្វី ហើយក៏មិនមានជំនាញអ្វីដែរ។ ពួកគេធ្វើការជាកម្មករ ប៉ុន្តែពួកគេមិនអាចរកការងារធ្វើបាននោះទេ។ អ្នកស្រីលី មើលឃើញថាគ្រួសារមួយនេះ ខិតខំប្រឹងប្រែងធ្វើការ និងពិតជាចង់ធ្វើការ ដូចនេះនាងបានទៅលេងគ្រួសារមួយទៀត

នៅក្នុងក្រុមជំនុំ ដែលជាកសិករដាំដំឡូងជ្វា។ នាងបានសួរពួកគេថា ការធ្វើការដាំដំឡូងជ្វាចំណេញដែរឬទេ តើវាមានទីផ្សារល្អដែរឬទេ ហើយអ្នកត្រូវការអ្វីខ្លះដើម្បីដាំដំឡូងជ្វា។ នៅពេលដែលនាងបានរៀនថាវាជាការងារដ៏ល្អមួយ នាងបានពន្យល់ទៅកាន់គ្រួសារនោះថា ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យស្រលាញ់អ្នកជិតខាង និងមើលថែអ្នកក្រីក្រ ហើយនាងបានសួរពួកគេថា តើពួកគេមានបំណងចង់បង្រៀនគ្រួសារក្រីក្រមួយពីរបៀបដាំដំឡូងជ្វាដែរឬទេ។ ពួកគេក៏យល់ព្រម។ អ្នកស្រីលីបានណែនាំគ្រួសារទាំងពីរឲ្យស្គាល់គ្នា។ គ្រួសារក្រីក្រនោះពិតជារំភើបដែលឥឡូវនេះពួកគេអាចធ្វើអ្វីបាន ហើយបានជួលដីមួយកន្លែងតូច និងអ្វីៗដែលត្រូវការដើម្បីចាប់ផ្តើម។ នៅចុងឆ្នាំ ពួកគេប្រមូលបានផលល្អ ហើយអាចមានលទ្ធភាពដើម្បីបង់ថ្លៃជួលដីបាន និងលុយសម្រាប់ទិញគ្រាប់ពូជ -ល- និងនៅតែអាចរកប្រាក់ចំណេញដល់ក្រុមគ្រួសាររបស់ពួកគេ។



**រឿងទី៣៖ អ្នកស្រីលី និង ការផ្សះផ្សានៅក្នុងគ្រួសារ**

នៅក្នុងគ្រួសារទី៣នេះ អ្នកស្រីលី ចង់ជួយកូនដែលបានបែកចេញពីឪពុកម្តាយរបស់គេ។ ឪពុកម្តាយនោះជឿថា គ្រួសារនេះ គឺគ្មានបានការ ហើយនឹងបរាជ័យ។ អ្នកស្រីបានជួបជាមួយគ្រួសារ ហើយបានព្យាយាមសម្របសម្រួលគ្រួសារទាំងមូល។ អ្នកលី ធានាថានាងនឹងជួបជាមួយគ្រួសារនោះឲ្យបានទៀងទាត់ ព្រមទាំងជួយឲ្យជីវិតរបស់ពួកគេប្រសើរឡើង ប្រសិនបើឪពុកម្តាយចង់ទទួលយកគ្រួសាររបស់ពួកគេវិញ និងជួយពួកគេបន្តិចបន្តួច។ ជាលទ្ធផល ឪពុកម្តាយបានសម្រេចចិត្តទុកចិត្តកូនប្រុស និងគ្រួសាររបស់ពួកគេម្តងទៀត ហើយបានសម្រេចចិត្តឲ្យប្រាក់ពួកគេមួយចំនួនខ្ចីដើម្បីចាប់ផ្តើមអាជីវកម្មសំណល់ដែក។ ឥឡូវនេះ កូនប្រុសរបស់គាត់ដើរទិញរបស់របរដែលប្រើហើយចាស់ៗធ្វើពីដែក និងលក់វាឲ្យហាងកែឆ្នៃ។ សព្វថ្ងៃនេះ គាត់អាចផ្គត់ផ្គង់គ្រួសាររបស់គាត់ និងមានសេចក្តីអំណរនូវអ្វីដែលគាត់រកបានប្រចាំថ្ងៃ។ គាត់មានអារម្មណ៍ថាគាត់មានសេចក្តីថ្លៃថ្នូរ។



**ការពិភាក្សានៅក្នុងក្រុមធំ**

- តើអ្នកស្រីលីបាននាំមកនូវការផ្លាស់ប្រែនៅក្នុងសហគមន៍របស់គាត់យ៉ាងដូចម្តេច?
- តើធ្លាប់អ្នកមានឱកាសធ្វើដូចជាអ្នកស្រីលី នៅក្នុងសហគមន៍របស់អ្នកដែរឬទេ? តើអ្នកបានធ្វើអ្វី?

- តើអ្នកស្រីលី បានធ្វើកិច្ចការមួយចំនួនដែលបានចែងនៅក្នុងការសិក្សាព្រះគម្ពីរ ស្ដីអំពីស្ត្រីមេម៉ាយ ដោយរបៀបណាខ្លះ?
    - *គាត់បានសម្គាល់លើមនុស្ស។ គាត់បានជ្រើសរើសគ្រួសារមួយចំនួន និងបានទៅសួរសុខទុក្ខពួកគេ។*
    - *គាត់មានសេចក្ដីអាណិតអាសូរចំពោះពួកគេ។ គាត់មានបំណងចិត្តដើម្បីជួយពួកគេ។*
    - *គាត់បានលើកទឹកចិត្តពួកគេ។*
    - *គាត់ហ៊ានប្រថុយ និងមានចិត្តខិតខំប្រឹងប្រែងធ្វើការ។ គាត់មិនគ្រាន់តែលើកទឹកចិត្តមនុស្សតែប៉ុណ្ណោះទេ តែព្យាយាមស្វែងរកវិធីសាស្ត្រដើម្បីជួយពួកគេ។*
    - *ទោះបីជានៅក្នុងសាច់រឿងមិនបញ្ជាក់យ៉ាងច្បាស់ពីចំណុចនេះក៏ដោយ ក៏គាត់ប្រាកដជាបានអធិស្ឋាន។*
    - *រួចហើយទទួលបានលទ្ធផល។*
    - *គាត់បានឲ្យពួកគេនៅតែបន្តទៅមុខទៀត។ គឺពួកគេផ្ទាល់ មិនមែនអ្នកស្រីទេ ដែលទៅលក់នៅផ្សារ និងធ្វើកសិកម្មដោយផ្ទាល់។*
    - *ថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់។ ទោះបីជាវាមិននិយាយនៅក្នុងរឿងនេះក៏ដោយ ប៉ុន្តែមនុស្សមួយចំនួនបានក្លាយជាគ្រិស្តបរិស័ទ។*
- តើយើងអាចរៀនបានមេរៀនអ្វីខ្លះ ពីអ្នកស្រីលី?
    - យើងត្រូវតែ<u>មានចិត្តជួយមនុស្ស</u> និងមានចិត្តចង់លះបង់ពេលវេលាដើម្បីធ្វើដូច្នោះផងដែរ។

    - យើងត្រូវតែចំណាយពេល<u>កសាងទំនាក់ទំនង</u>ជាមួយមនុស្សនៅក្នុងសហគមន៍របស់យើង ដែលត្រូវការជំនួយ។ យើងត្រូវតែទៅសួរសុខទុក្ខជាទៀងទាត់ដើម្បីកសាងទំនុកចិត្តជាមួយមនុស្ស។

    - យើងត្រូវតែ<u>ស្ដាប់ពួកគេ</u> មានមនុស្សជាច្រើនដែលស្ថិតនៅក្នុងកាលៈទេសៈលំបាក ហើយមានអារម្មណ៍ថា ត្រូវការនរណាម្នាក់ខ្វល់ខ្វាយ និងស្រលាញ់ពួកគេ។ ប្រសិនបើពួកគេមានអារម្មណ៍ថាមនុស្សខ្វល់ខ្វាយចំពោះពួកគេ នោះពួកគេនឹងចង់ស្ដាប់ដំបូន្មាន។ យើងត្រូវតែប្រាកដថា មិនមានចិត្តគំនិតថ្កោលទោសពួកគេ ប៉ុន្តែពិតជាចង់ជួយពួកគេ។ ប្រសិនបើពួកគេមានអារម្មណ៍ថា អ្នកកំពុងតែថ្កោលទោសពួកគេ នោះពួកគេនឹងមិនចង់ចែកចាយ ឬបើកចំហសម្រាប់អ្នកនោះទេ។

    - យើងត្រូវតែ<u>មានគំនិត</u>ដើម្បីជួយមនុស្សឲ្យមើលឃើញពីវិធីសាស្ត្រថ្មីៗ ដែលពួកគេអាចធ្វើកិច្ចការផ្សេងៗបាន។ ជាញឹកញាប់មនុស្សមិនដឹងពីរបៀបផ្លាស់ប្រែជីវិតរបស់ពួកគេ

ឡើយ។ អ្នកក្រតែងតែមានអារម្មណ៍ថា ពួកគេមិនអាចផ្លាស់ប្តូរស្ថានការណ៍របស់ពួកគេ ហើយឆាប់បោះបង់ចោលនូវការព្យាយាម ក្នុងការទទួលបាននូវជីវិតដែលខុសប្លែក។ ពួកគេត្រូវការនរណាម្នាក់ដែលចង់ធ្វើការជាមួយពួកគេ ហើយផ្តល់នូវគំនិតពីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីផ្លាស់ប្រែជីវិតរបស់ខ្លួន។

- ○ យើងត្រូវតែមានចិត្តចង់ធ្វើការ ដើម្បីឲ្យគំនិតនោះបានក្លាយជាការពិត។ អ្នកស្រីលីបាននាំមកនូវគ្រាប់ពូជដំបូង និងចាប់ផ្តើមដាំវាជាមួយស្ត្រីម្នាក់នោះ។ គាត់មិនគ្រាន់តែប្រាប់នាងថាត្រូវធ្វើអ្វីនោះទេ។ គាត់បានស្វែងរកមនុស្សម្នាក់ដែលមានចិត្តចង់ជួយបង្រៀនគ្រួសារនោះពីរបៀបដាំដំឡូងជ្វា និងជួយពួកគេស្វែងរកដីដែលពួកគេអាចប្រើបាន។ នៅក្នុងសាច់រឿងទី៣ គាត់បានទៅរកគ្រួសារមួយ ហើយជួយសម្របសម្រួលពួកគេ។ គាត់មិនគ្រាន់តែប្រាប់មនុស្សឲ្យធ្វើអ្វីនោះទេ គាត់ក៏បានធ្វើការយ៉ាងសកម្មដើម្បីជួយពួកគេដើម្បីចាប់ផ្តើមផងដែរ។

- ○ មានចិត្តដើម្បីចាប់ផ្តើមពីតូច។ មិនមែនគំនិតទាំងអស់នឹងនាំមកនូវការផ្លាស់ប្រែយ៉ាងរហ័សដូចនៅក្នុងរឿងនេះទេ។ ជួនកាលយើងត្រូវតែធ្វើការពីមួយជំហានទៅមួយជំហាន ដើម្បីជួយមនុស្ស។ សូមកុំរំពឹងថា មនុស្សគ្រប់គ្នានឹងផ្លាស់ប្តូរច្រើន ហើយលឿនឡើយ។ ចូរឲ្យពួកគេនូវជំហានដំបូងងាយស្រួល ដើម្បីឲ្យពួកគេសម្រេចបាន និងមានអារម្មណ៍ថាទទួលបានជោគជ័យ។ នៅពេលដែលពួកគេទទួលបានជោគជ័យជាមួយកិច្ចការតូច នោះពួកគេនឹងមានឆន្ទៈនឹងសាកធ្វើកិច្ចការធំម្តង។

**ក្រុមជំនួយ**

ពេលខ្លះវាពិបាកក្នុងការគិតពីគំនិតដើម្បីជួយមនុស្ស។ របៀបមួយដែលមានគំនិតបន្ថែមនោះ គឺចាប់ផ្តើមមានក្រុមជំនួយ។ ក្រុមនេះអាចជាក្រុមនៃមនុស្សដែលមកជួបជុំគ្នាជារៀងរាល់សប្តាហ៍ ដោយសារតែពួកគេមានចិត្តចង់ជួយមនុស្ស។ ពួកគេអាចអធិស្ឋានជាមួយគ្នា សម្រាប់មនុស្សដែលពួកគេម្នាក់ៗកំពុងតែជួយ និងចែករំលែកនូវផ្នែកដែលពួកគេចង់បានគំនិត ដើម្បីនាំការផ្លាស់ប្រែ។ ដោយរួមជាមួយគ្នា ក្រុមនោះនិងអាចគិតពីគំនិតច្រើនជាងមនុស្សតែម្នាក់។ សូមកុំភ្លេចទូលសុំប្រាជ្ញាមកពីព្រះជាម្ចាស់។

**នៅក្នុងក្រុមតូច**

សូមគិតពីរូបភាពនៃគ្រួសារនៅដើមមេរៀននេះ។ សូមគិតពីវិធីសាស្ត្រមួយចំនួន ដែលយើងអាចជួយពួកគេឲ្យផ្លាស់ប្រែស្ថានការណ៍របស់ពួកគេបច្ចុប្បន្ន ទៅជារូបភាពពីផែនការដែលព្រះជាម្ចាស់មានសម្រាប់ជីវិតរបស់ពួកគេ។

## ការសន្និដ្ឋាន

ទំនុកតម្កើង ១៣៩៖១៤-១៧

ពេលខ្លះវាងាយស្រួល ក្នុងការដែលជឿថាអតីតកាលរបស់យើងជាអ្នកកំណត់ពីអនាគតរបស់យើង។ ប្រសិនបើយើងកើតមកក្រ នោះយើងនឹងតែងតែក្ររហូត ហើយប្រសិនបើគ្រួសាររបស់យើងជាកសិករ ហើយនឹងនៅតែជាកសិកររហូត។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះជាម្ចាស់មានគម្រោងការសម្រាប់ជីវិតរបស់អ្នក។ យើងត្រូវបានបង្កើតឡើងយ៉ាងពិសេស ហើយព្រះជាម្ចាស់បានប្រទានមកឲ្យអ្នកនូវទេពកោសល្យ និងបុគ្គលិកលក្ខណៈដែលទ្រង់ចង់ឲ្យយើងមាន ហើយបានដាក់យើងនៅក្នុងគ្រួសារដែលទ្រង់ចង់ឲ្យយើងកើត។ ទ្រង់ចង់ឲ្យយើងប្រើអ្វីដែលទ្រង់បានប្រទានឲ្យយើង ដើម្បីនាំការផ្លាស់ប្រែ។ យើងម្នាក់ៗអាចនាំការផ្លាស់ប្រែលើកាលៈទេសៈដែលយើងជួបប្រទះ មិនថានៅក្នុងគ្រួសាររបស់អ្នក ឬជាមួយមនុស្ស ឬក៏ក្នុងសហគមន៍របស់អ្នក។ ព្រះជាម្ចាស់ប្រហែលជាត្រាស់ហៅអ្នក ឲ្យនាំការផ្លាស់ប្រែនៅក្នុងក្រុមជំនុំរបស់អ្នក ខេត្តរបស់អ្នក ឬប្រទេសរបស់អ្នកទាំងមូល។

## អនុវត្តន៍

ប្រាប់ទៅក្នុងក្រុមឲ្យសញ្ជឹងគិត និងអធិស្ឋានពីសំណួរទាំងពីរខាងក្រោមនេះ

- តើជីវិតរបស់អ្នកមានលក្ខណៈយ៉ាងណាដែរ? តើអ្នកជឿថា ព្រះជាម្ចាស់អាចផ្លាស់ប្រែអនាគតរបស់អ្នកដែរឬទេ? ចូរអធិស្ឋានសុំឲ្យព្រះជាម្ចាស់បង្ហាញអ្នកពីរបៀបផ្លាស់ប្រែអនាគតរបស់អ្នក។
- សូមចំណាយពេលវេលាគិតពីមនុស្សម្នាក់ ដែលអាចចាប់ផ្តើមជួយបាន។ តើអ្នកចង់ធ្វើជាផ្នែកមួយនៅក្នុងក្រុមជំនួយដែរឬទេ?

នៅពេលដែលក្រុមបានចំណាយពេលអធិស្ឋាន សូមសួរទៅកាន់អ្នកដែលមានចំណាប់អារម្មណ៍ចង់ចូលរួមនៅក្នុងក្រុមជំនួយ ជួបជាមួយអ្នកនៅម៉ោងសម្រាកបន្ទាប់។ សូមជួយពួកគេឲ្យចែកក្រុម ដែលក្នុង១ក្រុមមាន ៤ ទៅ៨នាក់ ហើយលើកទឹកចិត្តពួកគេឲ្យរៀបពេលដើម្បីជួបគ្នា។ ពន្យល់ពីការជួបជុំដំបូងរបស់ពួកគេ ថាពួកគេគួរតែជ្រើសរើសនរណាម្នាក់ដើម្បីជួយ។ ចាប់ផ្តើមដោយការចុះសួរសុខទុក្ខ។ អធិស្ឋានឲ្យគ្នាទៅវិញទៅមក ថាព្រះជាម្ចាស់នឹងជួយពួកគេនៅពេលដែលអ្នកចុះសួរសុខទុក្ខ។  ការជួបជុំលើកទី២ គឺរាយការណ៍ពីការចុះសួរសុខទុក្ខថាវាយ៉ាងណាដែរ ហើយចែករំលែកពីផ្នែកដែលអ្នកត្រូវការគំនិតដើម្បីជួយ។ នៅក្នុងក្រុម ចូរសុំប្រាជ្ញាមកព្រះជាម្ចាស់ ហើយប្រើការច្នៃប្រឌិតដែលទ្រង់ប្រទានឲ្យអ្នក ដើម្បីគិតពីវិធីសាស្រ្តដែលអាចជួយបាន។ ចូរចាំថា កុំព្យាយាមធ្វើអ្វីៗទាំងអស់ក្នុងពេលតែមួយ។ គ្រាន់តែជ្រើសរើសមួយផ្នែកតូចដើម្បីចាប់ផ្តើមជួយពួកគេ។

## មេរៀនទី៤

# ព្រះជាម្ចាស់បានប្រទានមក ឲ្យយើងច្រើនណាស់

**គោលបំណង**

១. ស្គាល់ពីអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង

២. យល់ច្បាស់ថា ធនធានធម្មជាតិ (និស្ស័យ) និងធនធានខាងវិញ្ញាណដែលនៅខាងក្នុងយើង សំខាន់ជាងធនធានធម្មជាតិក្រៅខ្លួនយើងទៅទៀត។

**សម្ភារៈដែលត្រូវការ**

- នាដកថាសម្រាប់លេងល្ខោន
- ការណែនាំសិក្សាព្រះគម្ពីរនៅក្នុងក្រុមតូច
- កញ្ចប់រូបភាពជំនួយដល់ការសិក្សា – កាតធនធាន

## សេចក្តីផ្តើម

*មុនពេលចាប់ផ្តើមបង្រៀន សុំសិស្សម្នាក់ឲ្យត្រៀមខ្លួនអានអត្ថបទសម្រាប់សម្តែងដូចខាងក្រោម។*

មានបុរសម្នាក់ដែលជាអ្នកជឿលើព្រះយេស៊ូបានចំណាយពេលជាមួយព្រះជាម្ចាស់ ហើយគាត់បានអាននៅក្នុង ម៉ាថាយ ២៥៖១៤-៣០។ គាត់បាននិយាយថា៖

«ខ្ញុំសង្ឃឹមថាខ្ញុំនឹងបានដូចជាអ្នកបម្រើដែលទទួលបានប្រាក់ប្រាំណែន ដើម្បីឲ្យខ្ញុំធ្វើអ្វីដែលល្អអស្ចារ្យថ្វាយព្រះជាម្ចាស់! ប៉ុន្តែខ្ញុំពិតជាអាណិតចំពោះអ្នកបម្រើដែលទទួលបានប្រាក់តែមួយណែន... ខ្ញុំគិតថាព្រះជាម្ចាស់ប្រហែលជាតឹងរឹងចំពោះគាត់ហើយមើលទៅ! ក៏ប៉ុន្តែវាមិនមែនជាករណីរបស់ខ្ញុំទេ ដោយសារតែខ្ញុំមិនគិតថា ខ្ញុំមានប្រាក់ណែន ឬអំណោយពិសេសដើម្បីបម្រើព្រះជាម្ចាស់ និងធ្វើការសម្រាប់ទ្រង់នោះទេ! ក្រៅពីនេះទៅទៀត ខ្ញុំក្រខ្លាំងណាស់!! តាមពិត ខ្ញុំមិនអាចជួយនរណាម្នាក់បានទេ ដោយសារតែខ្ញុំមានតម្រូវការច្រើនណាស់។ ឱព្រះអម្ចាស់អើយ! សូមជួយទូលបង្គំផង ហើយសូមប្រទានឲ្យខ្ញុំនូវប្រាក់ពីរ បីណែនដើម្បីប្រើប្រាស់ផង...»

- តើអ្នកបានឃើញអ្វីនៅក្នុងល្ខោននេះ?
- តើអ្នកជឿ (គ្រិស្តបរិស័ទ) ក្រីក្រម្នាក់នេះបាននិយាយអ្វី?
- តើការយល់ឃើញរបស់គាត់ត្រឹមត្រូវដែរឬទេ?

- ហេតុអ្វីបានជាគាត់គិតដូច្នេះ?

## ការសិក្សាព្រះគម្ពីរ

ចូរអានម៉ាថាយ ២៥៖១៤-៣០ នៅក្នុងក្រុមតូច

ខ ១៦-១៨

- តើអ្នកបម្រើបានធ្វើអ្វីជាមួយនឹងប្រាក់ណែនរបស់ពួកគេ?
- តើអ្នកគិតថាខ្លួនអ្នកដូចជាអ្នកបម្រើដែលប្រើប្រាស់ប្រាក់ណែនរបស់ពួកគេ ឬជាអ្នកបម្រើដែលកប់វាចោល?

ខ១៩-២៣

- តើម្ចាស់បានធ្វើអ្វី នៅពេលដែលគាត់ត្រឡប់មកវិញ?
- តើគាត់បាននិយាយអ្វីទៅកាន់អ្នកដែលបានពហុគុណប្រាក់ណែនរបស់ពួកគេ?

ខ ២៤-២៨

- តើមានបញ្ហាអ្វីចំពោះអ្នកបម្រើដែលយកប្រាក់ណែនរបស់ខ្លួនទៅកប់ទុក?
- តើម្ចាស់បាននិយាយអ្វីទៅកាន់គាត់?
- តើអ្នកគិតថា ហេតុអ្វីបានជាអ្នកជឿជាច្រើនមិនប្រើប្រាស់ប្រាក់ណែន (ព្រះអំណោយទាន) របស់ពួកគេ?
- តើយើងអាចធ្វើអ្វីបាន?

## ការយកឈ្នះលើការដោះសាររបស់យើង

សុំអ្នកស្ម័គ្រចិត្ត៥នាក់។ ឲ្យអ្នកទាំងប្រាំអាននូវការដោះសារទូទៅមួយចំនួន។

**មនុស្សចាស់** = «អូហ៎ ខ្ញុំប្រាថ្នាថាខ្ញុំនៅតែក្មេងដដែល។ នោះខ្ញុំនឹងមានថាមពលដើម្បីបម្រើព្រះជាម្ចាស់ជាមួយនឹងអំណោយទានរបស់ខ្ញុំ។ ឥឡូវនេះខ្ញុំចាស់ហើយ និងឆាប់ហត់នឿយទៀត។»

**ក្មេង** = «អូហ៎ ខ្ញុំសង្ឃឹមថាខ្ញុំចាស់ជាងនេះ។ នោះខ្ញុំនឹងមានឥទ្ធិពលច្រើន ហើយខ្ញុំអាចដឹកនាំមនុស្សឲ្យបម្រើព្រះជាម្ចាស់ជាមួយនឹងអំណោយទានរបស់ខ្ញុំ។ វាពិបាកខ្លាំងណាស់ឥឡូវនេះដោយសារតែខ្ញុំនៅក្មេងពេក។»

**អ្នកជំនួញ** = «អូហ៎ ខ្ញុំសង្ឃឹមថាខ្ញុំមានពេលច្រើនជាងនេះ។ ខ្ញុំពិតជារវល់ណាស់ជាមួយការងាររបស់ខ្ញុំ ហើយខ្ញុំមិនដែលមានពេលដើម្បីជួយអ្នកដទៃនោះទេ។»

**អ្នកគ្មានចំណេះដឹង** = «អូហ៎ ខ្ញុំសង្ឃឹមថាខ្ញុំមានចំណេះដឹងច្រើនជាងនេះ។ ខ្ញុំមិនដឹងអ្វីសោះពីសាសនា។ មានតែគ្រូគង្វាលរបស់ខ្ញុំទេ បានអាចជួយអ្នកដទៃបាន ដោយសារតែគាត់បានទៅរៀនសាលាព្រះគម្ពីរ និងបានចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗជាច្រើន។»

**អ្នកក្រ** = «អូហ៎ ខ្ញុំសង្ឃឹមថាខ្ញុំមានលុយច្រើនជាងនេះ។ នោះខ្ញុំនឹងអាចបម្រើព្រះជាម្ចាស់។ ឥឡូវនេះខ្ញុំពិតជាក្រខ្លាំងណាស់ មិនអាចជួយនរណាបានក្រៅពីខ្លួនឯងឡើយ។»

**ពិភាក្សានៅក្នុងក្រុមតូច**

- ក្នុងចំណោមការដោះសារខាងលើ តើអ្នកធ្លាប់ប្រើមួយណា?
- តើការដោះសារមួយណា ដែលអ្នកតែងតែឮពីមនុស្សនៅក្នុងក្រុមជំនុំរបស់អ្នក?
- តើអ្វីជាការដោះសាររបស់អ្នកបម្រើដែលកប់ប្រាក់ណែនរបស់គាត់ទុក?
- តើម្ចាស់អាចទទួលយកការដោះសាររបស់គាត់ដែរឬទេ?
- តើអ្នកគិតថា ព្រះជាម្ចាស់ទទួលយកការដោះសាររបស់យើងបានដែរឬទេ?
- តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីយកឈ្នះនូវការដោះសារទាំងនេះ?

## យើងត្រូវតែចាប់ផ្ដើមមើលឃើញអ្វីៗទាំងអស់ថា ព្រះជាម្ចាស់បានប្រទានមកឲ្យយើង

ជារឿយៗយើងតែងតែស្ដាប់នូវការកុហករបស់សាតាំង ហើយជឿថាយើងមិនមានអ្វីនោះទេ។ យើងប្រៀបធៀបខ្លួនយើងជាមួយអ្នកដទៃ ហើយឃើញតែអ្វីដែលយើងមិនមានតែប៉ុណ្ណោះ។ ថ្ងៃនេះយើងនឹងមើលម្ដងទៀត ដើម្បីឃើញអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។

ដើម្បីជួយយើងឲ្យគិតកាន់តែច្បាស់ថែមទៀត យើងនឹងពិចារណាលើចំណុចបីយ៉ាងដូចជា លក្ខណៈសម្បត្តិខាងក្នុង លក្ខណៈសម្បត្តិខាងក្រៅ និងព្រលឹងវិញ្ញាណ។

**<u>និស្ស័យក្នុងខ្លួន</u>** សំដៅទៅលើអំណោយទាន និងសមត្ថភាពទាំងអស់ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។ ឧទាហរណ៍៖ សមត្ថភាពក្នុងការនិយាយ សមត្ថភាពក្នុងការចម្អិនម្ហូប និងសមត្ថភាពក្នុងការបង្កាត់ភ្លើង...

**<u>ធម្មជាតិក្រៅខ្លួន</u>** សំដៅទៅលើអំណោយទានធនធានផ្សេងៗដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។ ឧទាហរណ៍៖ ទឹក ដី ព្រះអាទិត្យ សាលា -ល-។

**<u>ខាងវិញ្ញាណ</u>** សំដៅទៅលើអ្វីៗដែលយើងមាន ដោយសារតែទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់។ ឧទាហរណ៍៖ ការអស្ចារ្យ ការអធិស្ឋាន និងអំណាចរបស់ព្រះជាម្ចាស់ -ល-។

ត្រូវប្រាកដថាសិស្សរបស់អ្នកយល់ច្បាស់ពីភាពខុសគ្នារវាងចំណុចទាំងបីខាងលើ។ សូមចែកសិស្សចេញជាក្រុមៗ ហើយសុំឲ្យពួកគេចាប់ផ្តើមចែកកាតតាមចំណាត់ថ្នាក់នីមួយៗ (កញ្ចប់រូបភាពជំនួយដល់ការសិក្សា - កាតធនធាន) ជាអ្វីៗដែលពួកគេមាន និងមិនមាននៅក្នុងសហគមន៍របស់ពួកគេ។ នៅពេលដែលពួកគេធ្វើរួចរាល់ សុំឲ្យពួកគេគិតពីរបស់ប្រាំយ៉ាងបន្ថែមទៀតដែលពួកគេមាន។

សុំឲ្យសិស្សមើលលើចម្លើយរបស់ពួកគេ។ សួរពួកគេថា តើមាននរណាអត់មានអ្វីសោះទេ។

ខណៈដែលមានអារម្មណ៍ថាគ្មានអ្វីសោះ ការពិតគឺថាព្រះជាម្ចាស់បានប្រទានពរដល់យើង។ ទ្រង់បានប្រទានមកឲ្យយើងច្រើនណាស់។ ជាជាងការគិតពីអ្វីដែលយើងមិនមាន យើងត្រូវតែប្រើអ្វីដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។

អាននៅក្នុង ម៉ាថាយ ២៥៖២០-២៣ ម្តងទៀត

- តើមានអ្វីកើតឡើង នៅពេលដែលយើងប្រើនូវអ្វីដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង?
- តើយើងកំពុងតែប្រើប្រាស់នូវអ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើងដែរឬទេ?
- តើយើងអាចប្រើប្រាស់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង ឲ្យបានកាន់តែប្រសើរជាងនេះ ដោយរបៀបណា?

## កសិករ

តាមការស្រាវជ្រាវបានបង្ហាញថា ធនធានដែលមាននៅក្នុងយើងមានសារៈសំខាន់ជាងធនធានដែលនៅខាងក្រៅយើង។ ក្នុងនាមជាគ្រិស្តបរិស័ទ យើងគួរតែស្វែងយល់ពីធនធានខាងវិញ្ញាណ ដែលពិតជាមានសារៈសំខាន់ជាងនេះទៅទៀត ដោយសារតែវាអាចពហុគុណនូវធនធានធម្មជាតិរបស់យើង។

**<u>សូមអានរឿងខាងក្រោម ២</u>**

នៅក្នុងទឹកដីនៃប្រទេសខុនស្តាន់សា (Constanza) គឺជាដីដែលមានជីជាតិ។ នៅទីនោះមានទឹកច្រើន និងអាកាសធាតុអំណោយផលដល់ការដាំដំណាំផ្សេងៗ។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ជនជាតិជប៉ុនដែលបានរត់គេចខ្លួនពីបញ្ហាលំបាកផ្សេងៗនៅក្នុងប្រទេសជប៉ុន ក្រោយពីចប់សង្គ្រាមពួកគេបានមកតាំងទីលំនៅនៅតំបន់នេះ។ នៅពេលដែលពួកគេមកដល់លើកដំបូង ពួកគេគ្មានអ្វីនោះទេ មានតែខោអាវដែលពួកគេកំពុងស្លៀកពាក់តែប៉ុណ្ណោះ។ ពួកគេរស់នៅជាមួយប្រជាជនក្នុងតំបន់ និងធ្វើកសិកម្មជាមួយពួកគេ។

អស់រយៈ២០ឆ្នាំ ដែលជនជាតិជប៉ុនបានធ្វើជាកសិករ ពួកគេក៏បានក្លាយជាអ្នកមាន។ ពួកគេមានផ្ទះដ៏ស្រស់ស្អាត។ ទោះបីជាយ៉ាងណាក៏ដោយ កសិករនៅក្នុងតំបន់នៅតែក្រដដែល និងនៅតែតស៊ូដាំដំណាំឲ្យបានត្រឹមគ្រប់គ្រាន់សម្រាប់បរិភោគ។



តើវាអាចកើតឡើងដោយរបៀបណា? តើមានអ្វីបានកើតឡើង? ពួកគេមានធនធានខាងក្រៅដូចគ្នា។ អ្វីដែលខុសគ្នានោះគឺគំនិតរបស់ពួកគេ។ ជនជាតិជប៉ុនជឿថា អ្នកគួរតែខិតខំធ្វើការទោះជាស្ថិតនៅក្នុងកាលៈទេសៈលំបាកក៏ដោយ ហើយអ្នកមិនគួរបោះបង់ចោលនោះទេ។ ពួកកសិករនៅក្នុងតំបន់ជឿថា ជីវិតរបស់ពួកគេនឹងមិនផ្លាស់ប្រែនោះទេ។ ពួកគេជាជឿថា ដោយហេតុថាឪពុកម្តាយ និងដូនតារបស់ពួកគេក្រ ពួកគេនឹងនៅតែក្រដូចគ្នា។ នៅពេលមានជួបកាលៈទេសៈលំបាក ពួកគេមិនធ្វើអ្វីនោះទេ ដោយសារតែពួកគេជឿថាវាជាជោគវាសនារបស់ពួកគេ។

- តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ?
- តើគំនិតរបស់មនុស្សមានសារៈសំខាន់ប៉ុណ្ណា?
- តើយើងរៀនបានអ្វីខ្លះពីសាច់រឿងនេះ?
- តើអ្វីមួយ ដែលយើងគួរតែធ្វើឲ្យខុសប្លែកពីលទ្ធផលនៃរឿងនេះ ដែរឬទេ?

(ជួយឲ្យសិស្សយល់ថា យើងមានដីដូចគ្នា។ អ្វីដែលខុសគ្នានោះគឺជំនឿ និងគំនិតរបស់ពួកគេ។ ជនជាតិជប៉ុនមិនមានធនធានធម្មជាតិខាងក្រៅនោះទេ ប៉ុន្តែអ្វីដែលដូចគ្នានោះគឺពួកគេសុទ្ធតែជាកសិករ។ គុណសម្បត្តិនោះគឺ ជនជាតិជប៉ុនមានធនធានធម្មជាតិ (និស្ស័យ) ខាងក្នុងល្អប្រសើរជាង។ យើងក៏អាចមានធនធានធម្មជាតិខាងក្នុងល្អដែរ ប្រសិនបើយើងប្រើប្រាស់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីជះឥទ្ធិពលដល់គំនិត និងជំនឿរបស់យើង)

### មេរៀនទី៥

# សាតាំងគឺជាមេកុហក

**គោលបំណង៖**

ដើម្បីឲ្យយល់ពី

១. សាតាំងតែងតែកុហក សូម្បីតែអំពីកម្រិតនៃជំនឿរបស់យើងអំពីកិច្ចការផ្សេងៗដូចជា ការងារ សេចក្ដីសង្ឃឹម មនុស្សជាតិ ការបង្កើតរបស់ព្រះជាម្ចាស់ -ល- ។ ការកុហករបស់វាគឺចង់ឲ្យយើងស្ថិតនៅក្នុងភាពក្រីក្រ។

២. ក្នុងនាមជាគ្រិស្តបរិស័ទ យើងត្រូវតែស្គាល់សេចក្ដីពិត ដោយសារតែសេចក្ដីពិតនឹងរំដោះឲ្យយើងមានសេរីភាព។

៣. ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យនាំមនុស្សគ្រប់ជាតិសាសន៍ធ្វើជាសាវ័ករបស់ទ្រង់ ដែលរួមបញ្ចូលទាំងការនាំមកនូវសេចក្ដីពិតគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

**សម្ភារៈដែលត្រូវការ**

- កញ្ចប់រូបភាពជំនួយដល់ការសិក្សា — កាតនៃការកុហក

## សេចក្ដីផ្ដើម

អាន យ៉ូហាន ៨៖៤៤

- តើនៅក្នុងខនេះពណ៌នាយ៉ាងណាខ្លះពីអារក្ស?
- សូមប្រាប់ពីឧទាហរណ៍នៃកុហកដែលសាតាំងអាចនឹងប្រាប់យើង។
- តើការកុហករបស់សាតាំងជះឥទ្ធិពលដល់យើងដែរឬទេ សព្វថ្ងៃនេះ?

សាតាំងជាបិតានៃការកុហក។ ចាប់តាំងពីដំបូង វាកុហក ហើយវានៅតែបន្តកុហកមកដល់សព្វថ្ងៃនេះ។ វាចង់ឲ្យយើងក្លាយជាអ្នកក្រ និងស្រេកឃ្លាន។ វាដឹងថា ប្រសិនបើយើងធ្វើតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ នោះយើងនឹងទទួលបានព្រះពរពីព្រះជាម្ចាស់។ វាមិនចង់ឲ្យវាកើតឡើងនោះទេ ដូច្នេះហើយបានជាវាកុហកយើង។

## តើសាតាំងប្រាប់ការកុហកបែបណាខ្លះ?

សាតាំងកុហកយើងតាមរបៀបច្រើនណាស់។ ថ្ងៃនេះ យើងនឹងពិនិត្យទៅលើការកុហកដែលវាប្រាប់យើងដើម្បីធ្វើឲ្យក្រ។

មើលកាតកុហកនីមួយៗ (កញ្ចប់រូបភាពជំនួយដល់ការសិក្សា #5)។ ត្រូវប្រាកដថា សិស្សយល់ពីការកុហក។ សូមឲ្យសិស្សគិតពីការកុហក២ទៀត ដើម្បីដាក់វាចូលនៅក្នុងកាតណាដែលទំនេរ។

ដាក់កាតទាំងអស់នៅលើតុ ហើយប្រាប់សិស្សឲ្យដាក់ស្លឹកឈើ (គ្រាប់សណ្តែក/ឈើចាក់ធ្មេញ) នៅលើកាតកុហកនីមួយៗដែលពួកគេធ្លាប់ជឿ ឬក៏ជឿ។

ចែកសិស្សចេញជាក្រុម ហើយប្រាប់ពួកគេឲ្យពិភាក្សាលើការកុហកនីមួយៗ និងគិតពីអ្វីដែលជាសេចក្តីពិតរបស់ព្រះជាម្ចាស់ ទៅកាន់ការកុហកនោះ។ សុំឲ្យក្រុមនីមួយៗប្រាប់ត្រឡប់មកវិញ។

| | |
|---|---|
| ការងារគឺជាបណ្តាសារ និងជាបន្ទុកដ៏ធ្ងន់មួយ។ បើធ្វើការកាន់តែតិច កាន់តែល្អ។ | យើងត្រូវបានបង្កើតមកដើម្បីធ្វើការ។ អដាំធ្វើការមុនពេលមានអំពើបាប។ នេះជាផ្នែកមួយនៃសេចក្តីថ្លៃថ្នូររបស់យើង និងជារបៀបដែលយើងអាចថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ |
| យើងកើតមកក្រ ស្លាប់ទៅវិញក៏ក្រដែរ។ | ព្រះជាម្ចាស់នឹងប្រទានពរដល់យើង ប្រសិនបើយើងគោរពកោតខ្លាចទ្រង់។ |
| យើងពិតជាក្រខ្លាំងណាស់ ដូចនេះយើងមិនចាំបាច់ឲ្យអ្វីទេ។ អ្នកផ្សេងគួរតែឲ្យមកយើងវិញ។ | ទោះបីជាអ្នកក្របំផុត ក៏មិនអាចគេចវេសពីការឲ្យដែរ។ នៅក្នុងគម្ពីរម៉ាឡាគី ព្រះជាម្ចាស់បានប្រាប់មនុស្ស ថាពួកគេមិនបានពរទេ ដោយសារតែពួកគេមិនបានដាក់ព្រះជាម្ចាស់ជាទីមួយ។ ទ្រង់បានប្រាប់ពួកគេឲ្យល្បងលជាមួយទ្រង់ មើលថានឹងមានអ្វីកើតឡើង ប្រសិនបើពួកគេចាប់ផ្តើមឲ្យតាមអ្វីដែលទ្រង់បង្គាប់។ យើងត្រូវតែទទួលស្គាល់ថាព្រះជាម្ចាស់បានប្រទានអ្វីគ្រប់យ៉ាងមកឲ្យយើង ហើយទ្រង់ចង់ផ្គត់ផ្គង់នូវអ្វីដែលយើងត្រូវការ។ |

| | |
|---|---|
| ព្រះជាម្ចាស់ទ្រង់យកព្រះទ័យទុកដាក់តែនឹងរឿងខាងវិញ្ញាណ។ | ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ក្នុងផ្នែកទាំងអស់នៃជីវិតរបស់យើង។ អ្វីៗត្រូវបានបាក់បែកដោយសារតែអំពើបាប ហើយទ្រង់ចង់ស្តារឡើងវិញនូវគ្រប់ផ្នែកទាំងនៃជីវិតរបស់យើងត្រឡប់មកទ្រង់វិញ។ |
| ព្រះជាម្ចាស់គ្រាន់តែចង់យើងឲ្យផ្សាយដំណឹងល្អដល់មនុស្សដែលនៅជុំវិញយើងប៉ុណ្ណោះ ដូច្នេះយើងមិនចាំបាច់ខ្វល់ខ្វាយពីតម្រូវការផ្នែករូបកាយនោះទេ។ | ព្រះជាម្ចាស់បានប្រាប់យើងឲ្យស្រលាញ់មនុស្សដែលនៅជុំវិញយើង។ នៅពេលដែលទ្រង់ពណ៌នាពីសត្វចៀម និងសត្វពពែ គឺទ្រង់ចង់រំឭកយើងថាសេចក្តីស្រលាញ់គឺជាការផ្គត់ផ្គង់ម្ហូបអាហារ ទឹក និងជម្រក។ នៅពេលដែលសួរថាអ្នកដែលនៅជុំវិញយើងជានរណានោះ គឺព្រះយេស៊ូបានប្រាប់ពីសាច់រឿងដែលសាសន៍សាម៉ារីជួបជាមនុស្សមិនដែលស្គាល់ និងរងរបួសនៅតាមផ្លូវ ហើយបានជួយព្យាបាលគេ។ |
| យើងមិនអាចផ្លាស់ប្តូរជីវិតរបស់យើង ដោយគ្មានប្រាក់ឧបត្ថម្ភពីនរណាម្នាក់បានឡើយ។ | ព្រះជាម្ចាស់បានប្រទានពរមកយើងរួចទៅហើយ។ យើងត្រូវតែបើកភ្នែករបស់យើងឲ្យឃើញនូវអ្វីទាំងអស់ដែលទ្រង់បានប្រទានមកឲ្យយើង និងចាប់ផ្តើមប្រើប្រាស់វា។ នៅពេលដែលយើងចាប់ផ្តើមប្រើប្រាស់អ្វីដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង និងផ្តល់ពរដល់អ្នកដទៃ នោះទ្រង់នឹងប្រទានពរដល់យើង។ នៅក្នុងវគ្គទី១ យើងបាននិយាយពីអ្នកស្រីលី ដែលបានជួយមនុស្សដោយគ្រាន់តែផ្តល់គំនិតឲ្យពួកគេ។ |
| មនុស្សមួយចំនួនគ្រាន់បើជាងមនុស្សមួយចំនួនទៀត។ យើងមិនសំខាន់នោះទេ។ | យើងទាំងអស់គ្នាត្រូវបានបង្កើតមកជាតំណាងរបស់ព្រះជាម្ចាស់ ហើយព្រះស្រលាញ់យើងម្នាក់ៗខ្លាំងណាស់ បានជាទ្រង់បានប្រទានព្រះបុត្រារបស់ទ្រង់មកសុគតដើម្បីយើង។ នៅក្នុងព្រះរាជ្យ |

| | |
|---|---|
| | របស់ទ្រង់គ្មានវណ្ណៈទាបខ្ពស់នោះទេ។ ទ្រង់បានបង្កើតយើងម្នាក់ៗមក តាមលក្ខណៈដែលទ្រង់ចង់ឲ្យយើងមាន និងគម្រោងការដ៏ពិសេសដល់មនុស្សគ្រប់គ្នា។ |
| សារនៃដំណឹងល្អគឺគ្រាន់តែជះឥទ្ធិពលក្នុងជីវិតខាងវិញ្ញាណរបស់យើងតែប៉ុណ្ណោះ។ | ព្រះយេស៊ូបានសុគតដើម្បីស្តារគ្រប់ផ្នែកទាំងអស់នៃជីវិត មិនគ្រាន់តែខាងវិញ្ញាណតែប៉ុណ្ណោះទេ។ |

## តើការកុហកនេះមានផលប៉ះពាល់អ្វីខ្លះ?

ការកុហករបស់សាតាំងជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតរបស់យើង។

សូមអាននូវសាច់រឿងខាងក្រោម[៣]

ភាគច្រើននៃប្រទេសអ៊ីស្រាអែលគឺជាវាលខ្សាច់ដ៏ធំមួយ។ ទោះជាយ៉ាងណាក៏ដោយ មានអ្វីមួយចម្លែកពីវាលខ្សាច់នេះ។ ផ្នែកខ្លះនៃវាលខ្សាច់នេះគ្មានដំណាំអ្វីទេ ផ្នែកនោះគឺទទេ និងស្ងួតខ្លាំងណាស់។ ផ្នែកផ្សេងៗទៀតនៃវាលខ្សាច់នេះមានព្រៃឈើ។ ផ្នែកទាំងនោះបង្កើតផលផ្លែ និងផ្កាជាច្រើនដែលពួកគេអាចនាំចេញទៅជុំវិញពិភពលោក។ ហេតុអ្វីបានជាមានព្រៃឈើនៅជិតវាលខ្សាច់? ប្រជាជនដែលរស់នៅលើវាលខ្សាច់គឺជាជនជាតិអារ៉ាប់។ ពួកគេជឿថាព្រះអាឡស់បានដាក់បណ្តាសាដី។ ពួកគេមិនធ្វើអ្វីនោះទេ ដោយសារតែពួកគេជឿថាដីនោះមិនល្អ ហើយវានៅតែមិនល្អរហូត។ ប្រជាជនដែលរស់នៅលើដីនោះគឺជនជាតិយូដា។ ពួកគេជឿថានោះគឺជាទឹកដីសន្យាដែលព្រះជាម្ចាស់បានប្រទានមកឲ្យពួកគេ។ ពួកគេជឿថានោះជាដីដែលពោរពេញទៅដោយទឹកដោះ និងទឹកឃ្មុំយ៉ាងហូរហៀរដូចដែលបានសន្យានៅក្នុងព្រះគម្ពីរ។ ពួកគេជឿថា ព្រះគម្ពីបានប្រាប់ពួកគេឲ្យមើលថែរក្សាលើទឹកដីនោះ ហើយគ្រប់គ្រង និងធ្វើការលើវា។ ដូច្នេះពួកគេបានប្រើប្រាស់គំនិតច្នៃប្រឌិតរបស់ពួកគេ ដើម្បីយកឈ្នះលើបញ្ហាខ្វះទឹក។ ពួកគេបានរកឃើញដំណោះស្រាយជាច្រើន ហើយក៏បានដាំព្រៃឈើ។ ព្រះជាម្ចាស់បានប្រទានពរដល់ការខិតខំប្រឹងប្រែងរបស់ពួកគេ ហើយឥឡូវនេះពួកគេមានច្រើនជាងអ្វីដែលពួកគេប្រើទៅទៀត។

- តើអ្វីជាលក្ខណៈខុសគ្នារវាងជនជាតិអារ៉ាប់ និងជនជាតិយូដា?
- តើអ្វីជាលក្ខណៈខុសគ្នានៅក្នុងដីដែលផ្តល់ផល រវាងដីដែលជនជាតិអារ៉ាប់កាន់កាប់ និងដីដែលជនជាតិយូដាកាន់កាប់?

(ជួយឲ្យសិស្សឃើញថា ជនជាតិអារ៉ាប់បានជឿលើពាក្យកុហករបស់សាតាំង ហើយជាលទ្ធផលដីរបស់ពួកគេគឺគ្មានប្រយោជន៍អ្វីសោះ។ ជនជាតិយូដាបានជឿទៅនឹងសេចក្ដីពិតរបស់ព្រះជាម្ចាស់ ហើយពួកគេទទួលបានផលច្រើនណាស់ ដែលពួកគេមានគ្រប់គ្រាន់ដើម្បីនាំចេញ។)

សូមមើលទៅកាតនៃការកុហកម្ដងទៀត។ សម្រាប់ការកុហកនីមួយៗ សូមគិតពីភាពខុសគ្នារវាងបុគ្គលដែលជឿលើពាក្យកុហក និងបុគ្គលដែលជឿលើសេចក្ដីពិតរបស់ព្រះជាម្ចាស់។ ឧទាហរណ៍ទី១គឺ ការងារគឺជាបណ្ដាសារ។ ប្រសិនបើនរណាម្នាក់ជឿថាការងារគឺជាបណ្ដាសារនោះ ពួកគេនឹងមិនខិតខំប្រឹងប្រែងធ្វើការនោះទេ។ ពួកគេនឹងឈប់ធ្វើការ កាលណាពួកគេមានគ្រប់គ្រាន់ដើម្បីបរិភោគនៅថ្ងៃនោះ។ ពួកគេមិនរីករាយនឹងធ្វើការនោះទេ ហើយនឹងតែងតែរកវិធីសាស្រ្តណាដែលធ្វើការកាន់តែតិចតាមដែលអាចធ្វើបាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើបុគ្គលនោះជឿថាការងារនោះ គឺជាផ្នែកនៃសេចក្ដីថ្លៃថ្នូររបស់យើង និងជារបៀបមួយដែលយើងអាចថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ នោះពួកគេនឹងខិតខំប្រឹងប្រែងធ្វើការ។ ដោយសារតែការខិតខំប្រឹងប្រែងរបស់ពួកគេ នោះពួកគេនឹងរកបានកាន់តែច្រើន។ ពួកគេទំនងជាខិតខំតស៊ូបន្ថែមទៀត នៅពេលដែលជួបកាលៈទេសៈលំបាក ហើយពួកគេនឹងមិនងាយបោះបង់ចោលទេ។

សូមមើលពាក្យកុហកនីមួយៗនៅក្នុងក្រុម ហើយពិភាក្សាពីផលប៉ះពាល់នៃពាក្យកុហកនោះ។ សូមចែកចាយប្រាប់សិស្សនៅក្នុងថ្នាក់វិញបន្ទាប់ពីមើលរួច។

ប្រាប់សិស្សឲ្យស្រមៃពីការផ្លាស់ប្រែដែលពួកគេចង់ឃើញនៅក្នុងសហគមន៍របស់ពួកគេ ប្រសិនបើមនុស្សគ្រប់គ្នាជឿលើពាក្យកុហក ឬជឿសេចក្ដីពិត។ តើសហគមន៍របស់អ្នកនឹងកាន់តែប្រសើរឡើង ឬក៏កាន់តែអាក្រក់ទៅៗ? តើសហគមន៍របស់អ្នកទំនងជាដូចអ្វីដែលព្រះជាម្ចាស់ចង់បាន ឬតិចជាងនោះ?

ក្នុងនាមជាសិស្ស ចូរចំណាយពេលអធិស្ឋានថាព្រះជាម្ចាស់នឹងបំបែកអំណាចនៃការកុហកនៅក្នុងតំបន់របស់អ្នក នឹងជួយឲ្យគំនិតរបស់អ្នកបានពេញទៅដោយសេចក្ដីពិត។

## តើយើងអាចកម្ចាត់ពាក្យកុហកដោយរបៀបណា?

សូមអាននៅក្នុងយ៉ូហាន ៨៖៣១-៣២ *ពេលនោះព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ជនជាតិយូដា ដែលបានជឿលើព្រះអង្គថា «ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹងពាក្យរបស់ខ្ញុំ អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។ ³²អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនឹងរំដោះអ្នករាល់គ្នាឲ្យមានសេរីភាព»។*

- តើយើងស្គាល់សេចក្ដីពិតដោយរបៀបណា?
- តើសេចក្ដីពិតនឹងធ្វើអ្វី? (រំដោះឲ្យយើងមានសេរីភាពពីអ្វី?)

ប្រសិនបើយើងចង់មានសេរីភាពពីពាក្យកុហករបស់សាតាំង នោះយើងនឹងត្រូវការសេចក្ដីពិតដែលមកពីព្រះជាម្ចាស់។ ព្រះជាម្ចាស់បានសន្យាថានឹងប្រទានឲ្យគ្រិស្ដបរិស័ទនូវ «ព្រះវិញ្ញាណនៃសេចក្ដីពិត ដែលនឹងណែនាំយើងក្នុងការយល់ដឹងទាំងអស់» (យ៉ូហាន១៦៖១៣)។ ចូរអធិស្ឋានថាព្រះជាម្ចាស់នឹងបង្ហាញសេចក្ដីពិត ហើយចំណាយពេលអានព្រះគម្ពីរដើម្បីយល់ច្បាស់ពីសេចក្ដីពិត។ ចូរសុំឲ្យព្រះជាម្ចាស់ជួយអ្នកឲ្យយល់ច្បាស់ពីព្រះគម្ពីរ និងសេចក្ដីពិតរបស់ទ្រង់។

## មេរៀនទី៦

# ការវាយតម្លៃពីតម្រូវការ

**គោលបំណង**

១. ដើម្បីផ្តល់ព័ត៌មានពីសហគមន៍

២. ដើម្បីជួយទៅដល់ក្រុមឲ្យគិតពីរបៀបដែលសហគមន៍របស់ពួកគេអាចផ្លាស់ប្តូរ

៣. ដើម្បីជួយចាប់ផ្តើមរៀបផែនការនាំការផ្លាស់ប្តូរទៅក្នុងសហគមន៍របស់ពួកគេ

**សម្ភារៈដែលត្រូវការ**

- កាតទទេ
- ក្រដាសធំទទេ

## សេចក្តីផ្តើម

ជំហានបន្ទាប់ដើម្បីនាំការផ្លាស់ប្រែទៅកាន់សហគមន៍របស់យើង គឺពិនិត្យមើលសហគមន៍របស់យើងឲ្យកាន់តែច្បាស់ និងយល់ច្បាស់អំពីអ្វីដែលជាបញ្ហាដែលយើងកំពុងជួបប្រទះ និងអ្វីដែលជាសេចក្តីសង្ឃឹមសម្រាប់អនាគត។

ជ្រើសរើស «ប្រាក់រៀល» ជាប្រាក់ដែលតូចជាងគេនៅក្នុងរូបិយវត្ថុរបស់អ្នក ជាលុយដែលមនុស្សគ្រប់គ្នាស្គាល់។

សូមសួរទៅកាន់ក្រុមឲ្យឆ្លើយសំណួរដូចខាងក្រោម។ (សូមកែសម្រួលសំណួរទាំងនេះទៅជារូបិយវត្ថុរបស់អ្នក ដើម្បីឲ្យសិស្សរបស់អ្នកស្គាល់។)

១. តើនៅលើរូបិយប័ណ្ណនេះ មានលេខ១000 ប៉ុន្មានកន្លែង?

២. តើនៅលើរូបិយប័ណ្ណនេះ មានពាក្យថា «មួយពាន់» ប៉ុន្មានកន្លែង?

៣. តើនៅលើរូបិយប័ណ្ណនេះ មានលេខសម្គាល់ (ស៊េរី) នៅកន្លែងណា?

៤. តើលេខសម្គាល់នេះមានពណ៌អ្វី?

៥. តើមានរូបអ្វីនៅផ្ទាំងខាងក្រោយនៃរូបិយប័ណ្ណនេះ?

៦. តើរូបនេះកំពុងតែធ្វើអ្វី?

៧. តើមានមនុស្សប៉ុន្មាននាក់ដែលនៅផ្ទាំងខាងក្រោយនៃរូបិយប័ណ្ណនេះ?

៨. តើមានពាក្យអ្វីដែលស្ថិតនៅផ្ទាំងខាងក្រោយ ផ្នែកខាងលើនៃរូបិយប័ណ្ណនេះ?

៩. តើវត្ថុតំណាងដែលនៅផ្នែកខាងឆ្វេងនៃផ្ទាំងខាងក្រោយមានពណ៌អ្វី?

សូមពន្យល់ទៅកាន់ពួកគេថា ជួនកាលយើងចំណាំ ឬស្គាល់ពីអ្វីមួយ រហូតដល់យើងលែងចាប់អារម្មណ៍នឹងវាទៀតហើយ។ គោលបំណងនៃលំហាត់ទាំងនេះ គឺដើម្បីជួយយើងឲ្យមើលឃើញពីសហគមន៍របស់យើងម្តងទៀត ហើយគិតពីអ្វីដែលយើងអាចជួយបាន។

## គ្រួសារ

គូរប្រអប់បីនៅលើផ្ទាំងក្រដាសធំ។ សរសេរនៅលើប្រអប់ទាំងនោះថា ក្រីក្រខ្លាំង ក្រីក្រ និង មាន។ នៅក្នុងប្រអប់នីមួយៗ ចូរពណ៌នាពីគ្រួសារដែលត្រូវនឹងអក្សរនៅលើប្រអប់នោះ។ ចូរប្រាប់ពួកគេឲ្យពិចារណាលើចំណុចមួយចំនួនដូចជា៖

- ប្រភេទផ្ទះ
- ម្ហូបអាហារ
- បសុសត្វ (សត្វចិញ្ចឹម)
- ដី
- សម្លៀកបំពាក់
- ការអប់រំ
- ការងារ

នៅពេលដែលពួកគេបំពេញរួចរាល់ហើយ សូមប្រាប់ពួកគេឲ្យប៉ាន់ស្មានពីភាគរយនៃមនុស្សនៅក្នុងសហគមន៍របស់ពួកគេ ដែលនៅក្នុងប្រអប់ទាំងបីនេះ។

**ឧទាហរណ៍**

| អ្នកមាន | អ្នកក្រ | អ្នកក្រខ្លាំង |
|---|---|---|
| ផ្ទះរឹងមាំ ស្រូវអង្ករនៅសល់ សំលៀកបំពាក់ស្អាតៗ។ ពួកគេមានទូរទស្សន៍ ម៉ូតូ ឌីវីឌី សត្វគោក្របីសាទ្បុង។ ពួកគេមានអាហារគ្រប់សម្រាប់មួយថ្ងៃ៣ពេល បូករួមទាំងសាច់ផងដែរ។ កូនៗមិនអត់ឃ្លានទេពេលទៅសាលា។ | ពួកគេមានតែផ្ទះទេ គ្មានអ្វីនៅក្នុងផ្ទះនោះទេ។ មានអាហារគ្រប់តែមួយពេលក្នុងមួយថ្ងៃ។ មានសម្លៀកបំពាក់តែ២ ឬ៣សម្រាប់តែប៉ុណ្ណោះ។ បរិភោគស្លឹកដំឡូងជ្វា។ | ផ្ទះបាក់បែក។ បរិភោគអាហារមួយពេលក្នុងមួយថ្ងៃ បាយជាមួយអំបិល។ មិនមានលទ្ធភាពបរិភោគអ្វីផ្សេងជាមួយទេ។ |

## សហគមន៍

ឲ្យអ្នកចូលរួមទាំងអស់ ធ្វើការជាមួយគ្នាដោយគូរផែនទីពីភូមិរបស់ពួកគេ។

ប្រសិនបើអ្នកកំពុងតែបណ្តុះបណ្តាលសហគមន៍ច្រើនជាងមួយ សូមចែកពួកគេចេញក្រុមតាមសហគមន៍របស់ពួកគេ។ ប្រសិនបើមានមនុស្សលើសពី៦នាក់ សូមចែកពួកគេចេញជា២ក្រុម ហើយឲ្យក្រុមនីមួយៗគូររូបផែនទី។

នៅពេលដែលគូរផែនទីរួចហើយ ឲ្យពួកគេគូសចំណាំចំណុចមួយចំនួនដូចខាងក្រោម៖

ក. កន្លែងដែលប្រជាជនបានទឹកដើម្បីទទួលទាន

ខ. សាលារៀន មន្ទីរពេទ្យ ផ្សារ មណ្ឌលសុខភាព -ល-

គ. កន្លែងសាសនាសំខាន់ ក្រុមជំនុំ ទីវត្តអារាម

ឃ. កន្លែងដែលមនុស្សទិញប្រេងឆាសម្រាប់ចម្អិនម្ហូប

ង. ផ្លូវសំខាន់ -ល-។

ច. តំបន់កម្សាន្ត

**ផែនទីគំរូ**

នៅពេលដែលគូរផែនទីរួច សូមឲ្យពួកគេប្រៀបធៀបផែនទីគ្នា ដើម្បីមើលពីអ្វីដែលខុសគ្នា និងអ្វីដែលដូចគ្នា។ ប្រសិនបើពួកគេមកពីសហគមន៍តែមួយ នោះពួកគេនឹងអាចទទួលបានគំនិតពីគ្នាទៅវិញទៅមក និងអ្វីៗដែលពួកគេនឹកមិនឃើញ។

នៅពេលដែលផែនទីបានបញ្ចប់ ចូរគូររូបផែនទី ទី២ ដែលនិយាយពីសហគមន៍របស់ពួកគេ ដែលពួកគេចង់បាននៅពេល ១០ឆ្នាំទៀត។ សុំឲ្យពួកគេពន្យល់ពីអ្វីដែលពួកគេបានបន្ថែមនៅលើផែនទី ហើយហេតុអ្វីដែលពួកគេបានផ្លាស់ប្តូរ។ តើវាខុសគ្នាពីផែនទី ទី១ យ៉ាងដូចម្តេច? ចូរសរសេរនូវគន្លឹះមួយចំនួនដែលផ្លាស់ប្រែនៅលើក្នុងទំព័រគន្លឹះផ្លាស់ប្រែសហគមន៍ នៃរបាយការណ៍នៃការបណ្តុះបណ្តាល។

## ការដាក់អាទិភាពលើគម្រោងនីមួយៗ

សូមគិតអំពីការផ្លាស់ប្តូរដែលអ្នកចង់ឃើញនៅក្នុងក្រុមគ្រួសារមួយចំនួន។ សូមសរសេរនៅលើកាតនីមួយ។ ចូរបន្ថែមការផ្លាស់ប្រែនៅលើផែនទីសហគមន៍ និងសរសេរវានៅលើកាត។ ដាក់កាតទាំងអស់ចូលគ្នា។ ប្រាប់សិស្សឲ្យលើកកាតទាំងអស់ ហើយមើលឃើញថាតើមានផ្លាស់ប្រែអ្វីខ្លះ ដែលពួកគេសង្ឃឹមថាវានឹងកើតឡើង ដែលមិនទាន់ត្រូវបានសរសេរបញ្ចូលនៅឡើយ។

សូមឲ្យសិស្សរៀបវាតាមចំណាត់ថ្នាក់ និងដាក់វាគរលើគ្នាតាម៖ សំខាន់ជាងគេ សំខាន់ មិនសូវសំខាន់។ សម្រាប់កាតណាដែលសំខាន់ជាងគេ ដាក់៣ពិន្ទុនៅលើវា។ សម្រាប់កាតណាដែលសំខាន់ដាក់២ពិន្ទុនៅលើវា។ សម្រាប់កាតណាដែលមិនសូវសំខាន់ដាក់១ពិន្ទុ។ ដាក់កាតចូលគ្នាម្តងទៀត ហើយឲ្យសិស្សរៀបវាតាមកម្រិតនៃភាពងាយស្រួលក្នុងការដោះស្រាយ។ ងាយស្រួលដោះស្រាយ  ធម្មតា  និងពិបាកក្នុងការដោះស្រាយ។ នៅលើកាតដែលងាយស្រួលដោះស្រាយ ដាក់៣ពិន្ទុ ហើយកាតដែលធម្មតា ដាក់២ពិន្ទុ រីឯកាតដែលពិបាកដោះស្រាយដាក់១ពិន្ទុ។

ចូរស្វែងរកកាតទាំងអស់ដែលមាន៦ពិន្ទុ (៥ពិន្ទុ ប្រសិនបើគ្មានកាតណាមាន៦ពិន្ទុ)។ នេះគឺជាកាតដែលសំខាន់ជាងគេផង និងងាយស្រួលដោះស្រាយជាងគេផង។ បន្ទាប់មករើសកាត១ ឬ២ ដើម្បីចាប់ផ្តើមធ្វើវា។

សូមចំណាយពេលអធិស្ឋាន នៅពេលដែលអ្នកបញ្ចប់ការបង្រៀនរបស់អ្នក ហើយសុំព្រះជាម្ចាស់ឲ្យនៅតែបន្តលើកិច្ចការរបស់អ្នក។ ប្រសិនបើមានពេល ចូរលើកទឹកចិត្តក្រុមឲ្យរៀបចំផែនការសម្រាប់សកម្មភាពនៃសេចក្តីស្រលាញ់បន្ទាប់របស់ពួកគេ។

---

[១] Allen, Scott D. (2011). Chapter 6: Wholistic Ministry Essentials. In Beyond the Sacred-Secular Divide (pp. 83-85). Seattle, WA: YWAM Publishing.

[២] Miller, Darrow, Bob Moffitt, and Scott Allen. (2005). Chapter 7: The ABCs of Culture. In The Worldview of the Kingdom of God (pp. 103-104). Seattle, WA: YWAM Publishing.

[៣]Miller, Darrow (2013) "13 Transforming Truths:  A Bible Study for Community Flourishing" (p5) published by the Disciple Nations Alliance under the terms of the Creative Commons Attribution-ShareAlike 3.0 license.